ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីបង្ហាញផ្លូវថ្នាក់ជាតិ ស្តីពី ការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

រាជធានីភ្នំពេញ ២០២៥

# អារម្ភកថា

ពិភពលោកយើងទទួលរងផលប៉ះពាល់កាន់តែខ្លាំងឡើង បណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កម្ពុជាត្រូវការប្រព័ន្ធប្រកាសឱ្យដឹងមុនត្រឹមត្រូវនិងទាន់ពេលវេលា។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) មានមោទនភាពក្រៃលែងក្នុងការបង្ហាញ "ផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា" ដែលជាក្របខ័ណ្ឌមួយគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងសមត្ថភាពក្នុងការត្រៀមបម្រុងនិងឆ្លើយតបទៅនឹងគ្រោះមហន្តរាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្កើតផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា ដោយមានការគាំទ្រយ៉ាងមុតមាំពីអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា តំណាងដោយកម្មវិធីស្បៀងអាហារពិភពលោកនិងដៃគូអន្តរជាតិសំខាន់ៗ រួមមាន ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(UNDRR) អង្គការឧតុនិយមពិភពលោក(WMO) សហភាពទូរគមនាគមន៍អន្តរជាតិ(ITU) និងសហព័ន្ធអន្តរជាតិនៃកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម(IFRC) ដែលបានណែនាំក្នុងការរៀបចំអភិក្រមនៃប្រព័ន្ធប្រកាសឱ្យដឹងមុននេះ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកាកបាទក្រហមកម្ពុជា និងក្រសួងនាំមុខក្នុងវិស័យនានា ពោលគឺក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ការចូលរួមចំណែកក្នុងការបង្កើតផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់នេះ។ កិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធនានា ពិតជាបានពង្រឹងនូវគុណភាពផែនទីបង្ហាញផ្លូវ ដើម្បីធានាការឆ្លើយតបនូវតម្រូវការពិតប្រាកដរបស់សហគមន៍មូលដ្ឋាន ក៏ដូចជារបស់ប្រទេសជាតិទាំងមូល។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការិយាល័យអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោក(WFP) ដែលបានគាំទ្រនិងចូលរួមដឹកនាំក្នុងការរៀបចំផែនទីបង្ហាញផ្លូវរបស់យើងដែលអនុលោមទៅនឹងឧត្តមានុវត្តន៍ជាអន្តរជាតិ។

យើងក៏សូមទទួលស្គាល់ការរួមចំណែកយ៉ាងសំខាន់របស់ស្ថាប័នដឹកនាំសសរស្តម្ភសកល ដែលរួមមានការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ អង្គការឧតុនិយមពិភពលោក សហភាពទូរគមនាគមន៍អន្តរជាតិ និងសហព័ន្ធអន្តរជាតិនៃកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម។ ការណែនាំនៃសសរស្តម្ភនីមួយៗ បានពង្រឹងការយល់ដឹងនិងការអនុវត្តប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់យើងដោយប្រសិទ្ធភាព។

សូមថ្លែងអំណរគុណសម្រាប់ការចូលរួមរបស់ក្រសួងសំខាន់ៗ រួមមានក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ពិតជាមានសារៈសំខាន់សម្រាប់ការធានានូវអភិក្រមគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្ន នៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សេចក្តីទុកចិត្តជូន គ.ជ.គ.ម. នូវតួនាទីដ៏សំខាន់ដើម្បីសម្របសម្រួល និងដឹកនាំការអនុវត្តលើគំនិតផ្តួចផ្តើមស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា (EW4All)។ ការទទួលខុសត្រូវនេះ គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារអាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងដំណើរឈានទៅមុខជាមួយនឹងផែនទីបង្ហាញផ្លូវនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញនូវការយកចិត្តទុកដាក់ខ្ពស់ និងការលះបង់របស់យើងក្នុងការជំរុញវប្បធម៌នៃការត្រៀមបម្រុង និងការបង្កើនភាពធន់របស់ប្រជាជនកម្ពុជាទាំងអស់។ តាមរយៈការរួបរួមគ្នា យើងអាចពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់យើង និងធានាថាព័ត៌មានទាន់ពេលវេលា បានទៅដល់អ្នកមានតម្រូវការបំផុត ដែលជួយកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយមកលើសង្គមរបស់យើង។

ថ្ងៃចន្ទ ២កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**
**អនុប្រធានទី១**

**កិត្តិសង្គហបណ្ឌិត គន់ គីម**

# មាតិកា


អារម្ភកថា ..... 2

១- សេចក្តីផ្តើម ..... 6

២- បញ្ហាប្រឈម ..... 7

៣- ទស្សនាទានរួម ..... 8

៤- គោលបំណងនិងគោលដៅ ..... 9

៥- យុទ្ធសាស្រ្តនិងសកម្មភាព ..... 10

៦- យន្តការអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្ត ..... 11

  ៦.១- ភាគព្វកិច្ចសម្របសម្រួល ..... 11

  ៦.២- ស្ថាប័នដឹកនាំនិងអនុវត្ត ..... 12

  ៦.៣- ការតាមដាននិងការវាយតម្លៃ ..... 13

៧- ប្រភពធនធាន ..... 13

៨- ការគ្រប់គ្រងហានិភ័យ ..... 20

៩- សេចក្តីសន្និដ្ឋាន ..... 21

ផែនការសកម្មភាពនៃផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការពង្រីកប្រព័ន្ធប្រកាសឱ្យដឹងមុន ..... 22

ឧបសម្ព័ន្ធ (១)– លទ្ធផលនៃការវិភាគគម្លាតក្នុងប្រព័ន្ធប្រកាសអាសន្ននៅកម្ពុជា ..... 48

## ១- សេចក្ដីផ្ដើម

ព្រះរាជាណាចក្រកម្ពុជា ជាញឹកញាប់រងគ្រោះដោយគ្រោះមហន្តរាយទឹកជំនន់ រាំងស្ងួត ខ្យល់កន្ត្រាក់ ដែលបានបង្កផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការធ្វើឱ្យខូចខាតដល់ផលិតកម្មកសិកម្ម និងបង្កជាឧបសគ្គដល់ការអភិវឌ្ឍទៀតផង។ ផលប៉ះពាល់នៃគ្រោះមហន្តរាយនៅកម្ពុជា ដែលបណ្ដាលមកពីហានិភ័យអាកាសធាតុ បានបន្សល់ទុកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរបស់ប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយ៩០%នៃប្រជាជនកម្ពុជាប្រកបរបរកសិកម្ម ដែលស្មើនឹងប្រមាណ ២៧%នៃផលិតផលក្នុងស្រុកសរុប ក្នុងនោះរបរនេសាទបានរួមចំណែកប្រមាណ១២%នៃផលិតផលក្នុងស្រុកសរុប(ធនាគារពិភពលោកឆ្នាំ២០២០)។ យោងតាមការប៉ាន់ប្រមាណរបស់ធនាគារពិភពលោក (Climate Change Knowledge Portal) ចំនួនមនុស្សដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយគ្រប់ប្រភេទ(គ្រោះរាំងស្ងួត ទឹកជំនន់ ជំងឺរាតត្បាត និងព្យុះ) ក្នុងរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ២០១០-២០២០ មានចំនួនប្រមាណ៧,៤លាននាក់។ ជាក់ស្ដែងបាតុភូតអែលនីញ៉ូ(El Niño) ឆ្នាំ២០១៥ បានជំរុញឱ្យមានគ្រោះរាំងស្ងួតរយៈពេល២ឆ្នាំជាប់គ្នា ដែលបណ្ដាលឱ្យប្រជាជនកម្ពុជាប្រមាណ២,៥លាននាក់នៅទូទាំង ១៨រាជធានី ខេត្ត ខ្វះខាតទឹកប្រើប្រាស់ ខូចខាតផលដំណាំ និងងាប់សត្វពាហនៈ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងក្របខ័ណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ទទួលស្គាល់ប្រព័ន្ធប្រកាសឱ្យដឹងមុនថាជាធាតុផ្សំដ៏សំខាន់ ដើម្បីឆ្ពោះទៅរកការកសាងសង្គមដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ប្រព័ន្ធប្រកាសឱ្យដឹងមុន គឺជាសមាសធាតុសំខាន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ព្រោះវាជួយកាត់បន្ថយឬបញ្ចៀសផលប៉ះពាល់ដ៏អាក្រក់នៃព្រឹត្តិការណ៍គ្រោះថ្នាក់អាកាសធាតុ និងអាចផ្ដល់ផលចំណេញប្រមាណដប់ទ្វេគុណលើការវិនិយោគ។ ដើម្បីឱ្យមានប្រសិទ្ធភាព ប្រព័ន្ធប្រកាសឱ្យដឹងមុនចាំបាច់ត្រូវមានលក្ខណៈជាការទទួលបានព័ត៌មានអំពីហានិភ័យ មានគោលដៅចំពោះសហគមន៍ដែលប្រឈមនឹងហានិភ័យខ្ពស់ ផ្សព្វផ្សាយសារប្រកាសអាសន្នប្រកបដោយប្រសិទ្ធភាព ធានាបាននូវការត្រៀមបម្រុង និងគាំទ្រដល់សកម្មភាពត្រៀមទុកមុន។ ប្រព័ន្ធប្រកាសឱ្យដឹងមុនត្រូវតែផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសមានភាពប្រាកដនិយម ហើយត្រូវយកប្រជាជន និងវិស័យដែលងាយរងគ្រោះបំផុតជាគោលដៅចម្បង។ ក្នុងន័យនេះ ប្រព័ន្ធប្រកាសឱ្យដឹងមុនត្រូវទទួលយកនូវអភិក្រមដែលផ្អែកលើប្រព័ន្ធ រួមបញ្ចូលនូវកត្តាហានិភ័យពាក់ព័ន្ធទាំងអស់ រាប់ទាំងការកើតឡើងពីគ្រោះថ្នាក់អាកាសធាតុ ឬភាពងាយរងគ្រោះសង្គម និងដំណើរការរយៈពេលខ្លីឬរយៈពេលវែងផងដែរ។

ប្រព័ន្ធប្រកាសឱ្យដឹងមុន រួមមានសសរស្តម្ភសំខាន់ចំនួនបួនៈ

- សសរស្តម្ភទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ
- សសរស្តម្ភទី២ : ការកំណត់ ការត្រួតពិនិត្យ ការវិភាគ និងការព្យាករ
- សសរស្តម្ភទី៣ : ការផ្សព្វផ្សាយស្តីពីការប្រកាសអាសន្ននិងទំនាក់ទំនង
- សសរស្តម្ភទី៤ : ការត្រៀមបម្រុងដើម្បីឆ្លើយតបទៅនឹងការប្រកាសអាសន្ន

ទិដ្ឋភាពសំខាន់ៗផ្សេងទៀតនៃប្រព័ន្ធប្រកាសឱ្យដឹងមុន រួមមានការសម្របសម្រួលពហុភាគី និងឆ្លងវិស័យ ការចូលរួមរបស់សហគមន៍ដែលមានហានិភ័យ បរិយាកាសអំណោយផលពីស្ថាប័ននិងបទប្បញ្ញត្តិ តួនាទីនិងទំនួលខុសត្រូវច្បាស់លាស់ និងសមត្ថភាពប្រតិបត្តិការគ្រប់គ្រាន់។

**ការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា** (EW4All) គឺជាគំនិតផ្តួចផ្តើមពិសេសមួយដែលត្រូវបានប្រកាសដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ មានគោលបំណងឆ្ពោះទៅរកសកម្មភាពដឹកនាំដើម្បីធានាថាមនុស្សគ្រប់រូបនៅលើផែនដី ត្រូវបានការពារដោយប្រព័ន្ធប្រកាសឱ្យដឹងមុននៅត្រឹមឆ្នាំ២០២៧។ គំនិតផ្តួចផ្តើមស្តីពីប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា រួមបញ្ចូលនូវសសរស្តម្ភគ្រឹះទាំងបួននៃប្រព័ន្ធប្រកាសឱ្យដឹងមុន ដោយ**ការយកប្រជាជនជាគោល មានដំណើរការពេញលេញ និងគ្របដណ្តប់លើពហុគ្រោះថ្នាក់**។ ក្រោមឆត្រនៃគំនិតផ្តួចផ្តើមស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា កម្ពុជាមានបំណងពង្រឹងកិច្ចខិតខំរបស់ខ្លួនដែលបាននិងកំពុងបន្ត និងពង្រឹងបន្ថែមទៀតលើប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់ជាតិ។

## ២- បញ្ហាប្រឈម

ប្រទេសកម្ពុជាមានភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុមួយចំនួន ជាពិសេសទឹកជំនន់ (ប្រជាជនប្រមាណ៣,៥លាននាក់ ឬ ២១% នៃចំនួនប្រជាជនសរុប) គ្រោះរាំងស្ងួត (៥,២លាននាក់ ឬ ៣១%) និងខ្យល់ព្យុះដែលជាគ្រោះថ្នាក់ធម្មជាតិដ៏សំខាន់។ យោងតាមសន្ទស្សន៍នៃហានិភ័យនៅឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាកំពុងឈរនៅលេខរៀងទី៦១ ក្នុងចំណោមប្រទេស១៩១ ដោយសារតែកម្ពុជាមានភាពប្រឈមនិងភាពងាយរងគ្រោះខ្ពស់។ ប្រជាជនប្រមាណ២,៦លាននាក់(១៧% នៃចំនួនប្រជាជនសរុប) រស់នៅក្នុងស្ថានភាពក្រីក្រ (ធនាគារពិភពលោក ឆ្នាំ២០២២)។ បើគ្មានវិធានការបន្សាំនិងកាត់បន្ថយបានត្រឹមត្រូវទេ គេបានរំពឹងថាការប្រែប្រួលអាកាសធាតុនឹងនាំឱ្យមានការកើនឡើងនូវប្រេកង់ អាំងតង់ស៊ីតេ និងភាពធ្ងន់ធ្ងរនៃគ្រោះមហន្តរាយ ហើយប្រការនេះនឹងធ្វើឱ្យខាតបង់សេដ្ឋកិច្ចហូតដល់៩% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជានៅឆ្នាំ២០៥០ ខណៈដែលអត្រាភាពក្រីក្រអាចកើនឡើងប្រមាណ៦% បន្ថែមទៀតនៅឆ្នាំ២០៤០ (ធនាគារពិភពលោក, ២០២៣)។

ការប្រែប្រួលអាកាសធាតុបាននិងកំពុងប៉ះពាល់យ៉ាងខ្លាំង ដល់ប្រជាជនដែលងាយរងគ្រោះពិសេសអ្នកមានពិការភាព ស្ត្រី កុមារ និងអ្នករស់នៅក្នុងភាពក្រីក្រ ដែលធ្វើឱ្យពួកគេងាយទទួលរងគ្រោះថ្នាក់ចំពោះគ្រោះមហន្តរាយ។ ប្រការនេះនឹងជំរុញឱ្យមានវិសមភាពសង្គម និងបញ្ហាប្រឈមនានាកាន់តែធ្ងន់ធ្ងរ ដែលចាំបាច់ត្រូវការប្រព័ន្ធប្រកាសឱ្យដឹងមុនប្រកបដោយបរិយាបន្ន ដើម្បីត្រៀមដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ប្រព័ន្ធទាំងនេះ ត្រូវផ្តល់ព័ត៌មានច្បាស់លាស់ អាចទទួលបានក្នុងទម្រង់ផ្សេងៗ និងត្រូវពិចារណាលើពេលវេលាបន្ថែម ដែលត្រូវការសម្រាប់ការត្រៀមខ្លួនរបស់ក្រុមមនុស្សចាស់ អ្នកមានកូនតូច

និងអ្នកមានពិការភាព ព្រមទាំងធានានូវផ្លូវជម្លៀសដែលគ្មានឧបសគ្គ និងមានការចូលរួមយ៉ាងសកម្មពីសហគមន៍ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការផ្តល់អាទិភាពដល់ការរៀបចំប្រព័ន្ធប្រកាសឱ្យដឹងមុនប្រកបដោយបរិយាបន្ន អាចបង្កើនភាពធន់របស់ប្រជាជនដែលងាយរងគ្រោះ និងជួយកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ ទៅលើអ្នកដែលមានស្ថានភាពហានិភ័យគ្រោះថ្នាក់បំផុត។

ប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់កម្ពុជា និងសមត្ថភាពត្រៀមបម្រុងឆ្លើយតបរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ ពិតជាមានសារៈសំខាន់ ប៉ុន្តែយើងមានបញ្ហាប្រឈមមួយចំនួន ដូចជាបញ្ហាហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ខ្វះខាតថវិកា និងគម្លាតក្នុងជំនាញបច្ចេកទេស។ ដូច្នេះការបង្កើតយន្តការប្រព័ន្ធប្រកាសឱ្យដឹងមុនដែលអាចទុកចិត្តបានតាមរយៈដំណើរការ ដែលផ្តល់ព័ត៌មាន ឬការប្រកាសដំណឹងអំពីហានិភ័យដល់ប្រជាជនគឺជាការចាំបាច់ ដើម្បីបង្កើនការត្រៀមបម្រុងសម្រាប់ព្រឹត្តិការណ៍គ្រោះមហន្តរាយនាពេលអនាគត។

## ៣- ទស្សនាទានរួម

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានផ្តល់អាទិភាពដល់ការអនុវត្តផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា (EW4ALL) ដោយបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធានាបាននូវការជូនដំណឹងអំពីការគំរាមកំហែងនៃមុខសញ្ញាគ្រោះថ្នាក់ ដោយរួមបញ្ចូលនូវការណែនាំអំពីសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តទាន់ពេលវេលាសម្រាប់ប្រជាពលរដ្ឋទាំងអស់។ ដោយទទួលស្គាល់នូវបញ្ហាប្រឈមសំខាន់ៗដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ រាជរដ្ឋាភិបាលយល់ថា ការប្រកាសឱ្យដឹងមុន ដែលមានប្រសិទ្ធភាពគឺដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ។

ការអនុវត្តផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា ស្របតាមគោលដៅដ៏ទូលំទូលាយរបស់កម្ពុជាក្នុងការបង្កើននូវភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការពង្រឹងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ យើងបានទទួលស្គាល់ថាប្រព័ន្ធប្រកាសឱ្យដឹងមុនដែលមានដំណើរការល្អ មិនត្រឹមតែជួយសង្គ្រោះអាយុជីវិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពដោយកាត់បន្ថយនូវការខាតបង់សេដ្ឋកិច្ច ដែលទាក់ទងនឹងគ្រោះមហន្តរាយផងដែរ។

លើសពីនេះ គំនិតផ្តួចផ្តើមរៀបចំផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា សង្កត់ធ្ងន់លើកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធនានា រួមទាំងស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជន។ យុទ្ធសាស្ត្រពហុភាគីនេះជំរុញការទទួលខុសត្រូវរួមគ្នា និងបង្កើនប្រសិទ្ធភាពរួមនៃប្រកាសឱ្យដឹងមុន។ តាមរយៈការធ្វើការរួមគ្នា កម្ពុជាអាចប្រើប្រាស់ធនធាន ចំណេះដឹង និងជំនាញរបស់ខ្លួន ដើម្បីបង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុនដ៏ទូលំទូលាយមួយ ដោយដោះស្រាយនូវបញ្ហាប្រឈមដែលប្រទេសកំពុងជួបប្រទះ។

## ៤- គោលបំណងនិងគោលដៅ

ផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា(ឬផែនទីបង្ហាញផ្លូវ) ឆ្នាំ ២០២៥-២០២៨ ដើរតួជាមគ្គុទ្ទេសក៍យុទ្ធសាស្ត្រ ដើម្បីជំរុញគំនិតផ្តួចផ្តើមនៃប្រព័ន្ធប្រកាសឱ្យដឹងមុនគ្របដណ្តប់ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងដើម្បីនាំការវិនិយោគឆ្ពោះទៅរកការពង្រឹងនិងពង្រីកប្រព័ន្ធប្រកាសឱ្យដឹងមុន ដែលជាផ្នែកមួយនៃការគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា។ អង្គការដែលមានកម្មវិធីកំពុងឬគ្រោងអនុវត្តពាក់ព័ន្ធនឹងប្រព័ន្ធប្រកាសឱ្យដឹងមុន ត្រូវបានលើកទឹកចិត្តឱ្យបញ្ចូលសកម្មភាពទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រ ក្របខ័ណ្ឌប្រតិបត្តិ និងផែនការការងាររបស់ខ្លួន។

គោលបំណងចម្បងនៃផែនទីបង្ហាញផ្លូវនេះ គឺដើម្បីផ្តល់ឱ្យរដ្ឋាភិបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនូវ**ក្របខ័ណ្ឌរចនាសម្ព័ន្ធសម្រាប់ការពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុននៅទូទាំងប្រទេស ដោយយកប្រជាជនជាគោល**។ ផែនទីបង្ហាញផ្លូវនេះ ផ្តល់នូវ**សំណុំសកម្មភាព ដែលត្រូវបានរៀបចំឡើង ដើម្បីផ្តល់អាទិភាពសម្រាប់ការវិនិយោគជុំវិញប្រព័ន្ធប្រកាសឱ្យដឹងមុន និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** ស្របតាមគោលដៅ-G នៃក្របខ័ណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ[1] ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ២០១៥ ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០២៤-២០២៨ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត។

ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.) ដោយផ្អែកលើធាតុចូលពីសិក្ខាសាលាពិគ្រោះយោបល់ ក្រោមកិច្ចគាំទ្រពីអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា តំណាងដោយកម្មវិធីស្បៀងអាហារពិភពលោក ដែលជាស្ថាប័នបង្គោលសម្រាប់គំនិតផ្តួចផ្តើមស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា នៅកម្ពុជា និងស្ថាប័នដឹកនាំសកលនៃសសរស្តម្ភទាំងបួននៃគំនិតផ្តួចផ្តើមនេះ រួមមានការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(សសរស្តម្ភទី១) អង្គការឧតុនិយមពិភពលោក(សសរស្តម្ភទី២) សហភាពទូរគមនាគមន៍អន្តរជាតិ(សសរស្តម្ភទី៣) និងសហព័ន្ធអន្តរជាតិនៃកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម (សសរស្តម្ភទី៤)។ ធាតុចូលសំខាន់ៗសម្រាប់ការរៀបចំផែនទីបង្ហាញផ្លូវនេះ ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងកាកបាទក្រហមកម្ពុជា រួមជាមួយនឹងស្ថាប័នរដ្ឋាភិបាល និងភាគីមិនមែនរដ្ឋាភិបាលជាច្រើនទៀត។

អនុសាសន៍ដែលបានបង្ហាញក្នុងផែនទីបង្ហាញផ្លូវនេះ គឺផ្អែកលើលទ្ធផលនៃការវិភាគលើគម្លាត ការកំណត់អាទិភាព និងតម្រូវការចាំបាច់ នៃស្ថានភាពការងារតាមសសរស្តម្ភទាំងបួនរបស់ប្រព័ន្ធប្រកាសឱ្យដឹងមុនដែលបានអធិប្បាយខាងលើ។ ផ្នែកអន្តរសសរស្តម្ភរួមបញ្ចូលនូវសកម្មភាពអនុសាសន៍នៃអន្តរវិស័យ រួមមានអភិបាលកិច្ច ការសម្របសម្រួលអ្នកពាក់ព័ន្ធ ការតស៊ូមតិ ការត្រួតពិនិត្យនិងវាយតម្លៃ និងការផ្តល់

[1] គោលដៅ-G នៃក្របខ័ណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ មានគោលបំណងបង្កើនភាពអាចរកបាន និងលទ្ធភាពទទួលបានប្រព័ន្ធប្រកាសអាសន្នឱ្យដឹងមុនចំពោះពហុគ្រោះថ្នាក់, និងព័ត៌មាននិងការវាយតម្លៃអំពីហានិភ័យគ្រោះមហន្តរាយដល់ប្រជាជននៅឆ្នាំ២០៣០។ គោលដៅនេះសង្កត់ធ្ងន់លើសារៈសំខាន់នៃការធានាថាសហគមន៍មានសុខុមាលភាព។ បានជូនដំណឹង និងរៀបចំសម្រាប់ប្រភេទផ្សេងៗនៃគ្រោះថ្នាក់ បង្កើនភាពធន់ និងសមត្ថភាពក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព (UNFCCC, ឆ្នាំ២០២២)។

ហិរញ្ញប្បទាន សម្រាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន។ វិធីសាស្ត្រគ្រប់ជ្រុងជ្រោយនេះ មានគោលបំណងបង្កើតផែនការមួយដែលមានលក្ខណៈប្រមូលផ្តុំ ដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់កម្ពុជា។

## ៥- យុទ្ធសាស្ត្រនិងសកម្មភាព

ផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា ត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខ័ណ្ឌ និងគោលការណ៍សកលមួយចំនួននៃគំនិតផ្តួចផ្តើមនេះ រួមមានគោលការណ៍ណែនាំស្តីពីការអនុវត្តនិងដំណើរការដាក់លាក់សម្រាប់ប្រទេស ផែនការសកម្មភាពប្រតិបត្តិសកលឆ្នាំ២០២៣-២០២៧ និងការណែនាំសកលស្តីពីការរៀបចំកម្មវិធីប្រតិបត្តិនៅកម្រិតប្រទេស។ ដំណើរការរៀបចំផែនទីបង្ហាញផ្លូវនេះបានរួមបញ្ចូលនូវការស្រាវជ្រាវ និងការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងតាមរយៈសិក្ខាសាលាអ្នកពាក់ព័ន្ធជាច្រើន។

ការគូសផែនទីភាគីពាក់ព័ន្ធ បានចូលរួមដោយអង្គការ និងស្ថាប័នសំខាន់ៗជាច្រើន រួមមានស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជន។ គោលបំណង គឺដើម្បីកំណត់អំពីតួអង្គដែលមានសកម្មភាពពាក់ព័ន្ធនឹងប្រព័ន្ធប្រកាសឱ្យដឹងមុននៅកម្ពុជា ជុំវិញសសរស្តម្ភទាំងបួន។




សូមមើលឧបសម្ព័ន្ធ១ សម្រាប់លទ្ធផលទាំងស្រុងនៃការវិភាគម្លាតសមត្ថភាព។

តារាងសកម្មភាពផែនទីបង្ហាញផ្លូវនេះ (ផ្នែកទី៦) រួមជាមួយនឹងលទ្ធផលរំពឹងទុកតាមសសរស្តម្ភនីមួយៗ មានគូសបញ្ជាក់ផងដែរនូវតម្រូវការថវិកាតាមការប៉ាន់ស្មាន និងព័ត៌មានគម្រោងពាក់ព័ន្ធប្រព័ន្ធប្រកាសឱ្យដឹងមុនដែលកំពុងដំណើរការ ឬការវិនិយោគដែលបានគ្រោងទុក។ សកម្មភាពនៃផែនទីបង្ហាញ

ផ្លូវនេះ ត្រូវបានរៀបចំឡើងផ្អែកតាមតម្រូវការរបស់សសរស្តម្ភទាំងអស់ ដោយបានច្របាច់បញ្ចូលគ្នាទៅក្នុងបញ្ជីសកម្មភាពអាទិភាពដែលជាអនុសាសន៍ ដើម្បីផ្តល់នូវភាពងាយស្រួលសម្រាប់ម្ចាស់ជំនួយក្នុងការធ្វើសង្គតិភាពលើយុទ្ធសាស្ត្រ និងការវិនិយោគអាទិភាពរបស់ខ្លួន។ ផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នានេះ គឺជាឯកសាររស់ ដែលនឹងវិវឌ្ឍបន្តតាមរយៈការធ្វើបច្ចុប្បន្នភាពទៀងទាត់ដោយផ្អែកលើព័ត៌មានទទួលបានពីក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ដែលបានរៀបរាប់។

## ៦- យន្តការអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្ត

### ៦.១- ភាគពូកិច្ចសម្របសម្រួល

ការសម្របសម្រួលជារួមក្នុងការអនុវត្តសកម្មភាពនៃផែនទីបង្ហាញផ្លូវនេះ ត្រូវបានដឹកនាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) ដោយមានការគាំទ្រពីស្ថាប័នបង្គោលរបស់អង្គការសហប្រជាជាតិសម្រាប់គំនិតផ្តួចផ្តើម ស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នានៅកម្ពុជា គឺកម្មវិធីស្បៀងអាហារពិភពលោក និងក្រសួង ស្ថាប័ន ដែលដឹកនាំការអនុវត្តសកម្មភាពក្រោមសសរស្តម្ភនីមួយៗ រួមមានក្រសួងបរិស្ថាន សម្រាប់សសរស្តម្ភទី១, ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់សសរស្តម្ភទី២, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់សសរស្តម្ភទី៣ និង គ.ជ.គ.ម. រួមជាមួយនឹងកាកបាទក្រហមកម្ពុជា សម្រាប់សសរស្តម្ភទី៤។ មន្ត្រីបង្គោល និងមន្ត្រីតំណាងពីក្រសួង ស្ថាប័នដែលដឹកនាំសកម្មភាពនៃសសរស្តម្ភនីមួយៗដូចរៀបរាប់ខាងលើ នឹងត្រូវបានស្នើចាត់តាំងចូលរួម ដើម្បីធានាការងារសម្របសម្រួល និងអនុវត្តរបស់ផែនទីបង្ហាញផ្លូវនេះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសម្រាប់ការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា នឹងត្រូវបានបង្កើតឡើង ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធដៃគូអភិវឌ្ឍ និងវិស័យឯកជន ដូចបង្ហាញក្នុងដ្យាក្រាមទី១។ ការសម្របសម្រួលទូទៅនៃសមាជិកក្រុមការងារខាងលើ និងដៃគូពាក់ព័ន្ធ នឹងត្រូវបានដឹកនាំដោយលេខាធិការដ្ឋានចាត់តាំងមួយនៅក្នុងគ.ជ.គ.ម ដែលដឹកនាំដោយមន្ត្រីបង្គោលថ្នាក់ជាតិសម្រាប់ការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា ដែលត្រូវបានចាត់តាំងដោយរាជរដ្ឋាភិបាល។ កិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាស រវាងសមាជិកក្រុមការងារ អ្នកដឹកនាំតាមសសរស្តម្ភ និងស្ថាប័នដឹកនាំអនុវត្តសកម្មភាពពាក់ព័ន្ធ នឹងត្រូវបានរៀបចំនិងដឹកនាំសម្របសម្រួលដោយគ.ជ.គ.ម. ដោយមានការគាំទ្រពីកម្មវិធីស្បៀងអាហារពិភពលោក ឬអ្នកសម្របសម្រួលតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជាតាមភាពចាំបាច់។

ដ្យាក្រាមទី១ : រចនាសម្ព័ន្ធសម្របសម្រួលការអនុវត្តផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា

**អគ្គលេខាធិការដ្ឋាន គ.ជ.គ.ម.**

**ដៃគូអភិវឌ្ឍ**

- អ្នកសម្របសម្រួល UN ប្រចាំកម្ពុជា
- ស្ថាប័នបង្គោល UN សម្រាប់ EW4ALL
- អង្គភាពពាក់ព័ន្ធរបស់ UN
- អង្គការជាតិនិងអង្គការអន្តរជាតិ
- វិស័យឯកជននិងស្ថាប័នស្រាវជ្រាវ

**ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ**

- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកិច្ចការនារី
- វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- កាកបាទក្រហមកម្ពុជា

## ៦.២- ស្ថាប័នដឹកនាំនិងអនុវត្ត

ស្ថាប័នដឹកនាំនិងសម្របសម្រួល ស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នានៅកម្ពុជាគឺៈ

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ស្ថាប័នគាំទ្របច្ចេកទេសលើដំណើរការរៀបចំនិងអនុវត្ត ស្តីពីការប្រកាសឱ្យដឹងមុន សម្រាប់ទាំងអស់គ្នាគឺៈ

- អ្នកសម្របសម្រួលតំណាងអង្គការសហប្រជាជាតិប្រចាំប្រទេស និង
- អង្គការសហប្រជាជាតិ កម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា

ក្រសួង ស្ថាប័នអ្នកអនុវត្តសំខាន់ៗសម្រាប់ផែនទីបង្ហាញផ្លូវជាតិនេះ រួមមានស្ថាប័នដែលដឹកនាំសកម្មភាពនៃសសរស្តម្ភនីមួយៗ និងសហដឹកនាំកម្មវិធី ដែលមានដូចខាងក្រោមៈ

- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- កាកបាទក្រហមកម្ពុជា
- អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- អង្គភាពពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ

- សហព័ន្ធអន្តរជាតិកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម
- អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលពាក់ព័ន្ធ

ក្រសួង ស្ថាប័នដៃគូអនុវត្តសំខាន់ៗផ្សេងទៀត ដែលចាំបាច់សម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវនេះប្រកបដោយប្រសិទ្ធភាព រួមមាន៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកិច្ចការនារី
- វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប.) នៃក្រសួងមហាផ្ទៃ

### ៦.៣- ការតាមដាននិងការវាយតម្លៃ

ការត្រួតពិនិត្យលើការអនុវត្តសកម្មភាពផែនទីបង្ហាញផ្លូវអនុវត្តន៍ជាតិនេះ នឹងត្រូវប្រព្រឹត្តទៅតាមរយៈកិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាស ដែលសម្របសម្រួលដឹកនាំដោយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចបានរៀបរាប់ក្នុងផ្នែកទី៥។ របាយការណ៍តាមដានអំពីវឌ្ឍនភាពនៃសកម្មភាពអនុវត្ត ត្រូវបានរៀបចំដោយអគ្គលេខាធិការដ្ឋាន ដោយមានការគាំទ្រពីសមាជិកនៃក្រុមសម្របសម្រួលបច្ចេកទេស និងអ្នកសម្របសម្រួលតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជាតាមភាពចាំបាច់។

របាយការណ៍ទាំងនេះនឹងវាយតម្លៃលើវឌ្ឍនភាព កំណត់ឧបសគ្គ វាយតម្លៃហានិភ័យ និងជូនដំណឹងដល់អ្នកធ្វើការសម្រេចចិត្ត អំពីវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។ ការវាយតម្លៃក៏នឹងត្រូវធ្វើឡើងតាមពេលវេលាកំណត់ អាស្រ័យតាមតម្រូវការ ឬទម្រង់នៃការផ្តល់មូលនិធិនានាដែលគាំទ្រលើការអនុវត្តសកម្មភាពនៃផែនទីបង្ហាញផ្លូវអនុវត្តជាតិនេះ។ ការវាយតម្លៃលើវឌ្ឍនភាពនៃផែនទីបង្ហាញផ្លូវនឹងត្រូវបានពិនិត្យលើមូលដ្ឋានប្រចាំឆ្នាំ ដោយស្ថាប័នដឹកនាំនៃសសរស្តម្ភទាំងបួនរបស់គំនិតផ្តួចផ្តើមស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា។

## ៧- ប្រភពធនធាន

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបអំពីគម្រោងសំខាន់ៗដែលបានកំពុងដំណើរការ និងគ្រោងអនុវត្តដែលភាពពាក់ព័ន្ធនឹងសសរស្តម្ភទាំងបួននៃគំនិតផ្តួចផ្តើម ស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា ដោយមានបញ្ជាក់ពីដៃគូអនុវត្តផងដែរ។ សេចក្តីសង្ខេបនេះមានបំណងផ្តល់នូវទិដ្ឋភាពទូទៅនៃចំណុចស្នូលរបស់កម្មវិធី ការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ និងពេលវេលាសម្រាប់គំនិតផ្តួចផ្តើមឬគម្រោងនីមួយៗ។

### ៧.១- ក្រសួងធនធានទឹកនិងឧតុនិយម

**១- គម្រោងហានិភ័យអាកាសធាតុ និងប្រព័ន្ធប្រកាសឱ្យដឹងមុន (CREWS) សម្រាប់ប្រទេសកម្ពុជា និងប្រទេសឡាវ**

*អ្នកផ្តល់ជំនួយ : គំនិតផ្តួចផ្តើម CREWS; រយៈពេល : ២០២១-២០២៥ (CREWS ២.0 : ពាក់កណ្តាលឆ្នាំ២០២៥-២០២៩); ថវិកា : ៥លានដុល្លារ និង៧លានដុល្លារ បន្ថែមសម្រាប់ CREWS 2.0 សម្រាប់ប្រទេសទាំងពីរ*

គម្រោងនេះមានគោលបំណងពង្រឹង និងសម្រួលប្រព័ន្ធ និងសមត្ថភាពក្នុងតំបន់ និងថ្នាក់ជាតិទាក់ទងនឹងការព្យាករជាតុអាកាស សេវាកម្មជលសាស្ត្រ ការប្រកាសអាសន្នផ្អែកលើផលប៉ះពាល់ជាក់ស្តែងចំពោះពហុគ្រោះថ្នាក់ និងការផ្តល់សេវានាំទៅរកការសម្រេចចិត្តឱ្យបានកាន់តែប្រសើរ។ CREWS ២.0 នឹងផ្តោតលើការកសាងសមត្ថភាព ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការរួមបញ្ចូលប្រព័ន្ធប្រកាសឱ្យដឹងមុនជាមួយនឹងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ គម្រោងនេះគ្រប់គ្រងដោយអង្គការឧតុនិយមពិភពលោក ជាមួយនឹងការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងធនាគារពិភពលោក។ ក្រសួងធនធានទឹកនិងឧតុនិយម និង គ.ជ.គ.ម. គឺជាដៃគូប្រតិបត្តិដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា។

## ២- ការធ្វើឱ្យប្រសើរឡើងនូវបណ្តាញសង្កេតមូលដ្ឋានសកល (GBON) សម្រាប់នៅកម្ពុជា

*អ្នកផ្តល់ជំនួយ : Systematic Observation Financing Facility (SOFF); រយៈពេល : ២០២៣-២០២៨; ថវិកា : ៥លានដុល្លារ*

គម្រោងនេះមានគោលបំណងជួយធ្វើឱ្យប្រព័ន្ធសង្កេតជាតុអាកាសរបស់កម្ពុជា អាចបំពេញតាមតម្រូវការអប្បរមារបស់បណ្តាញសង្កេតមូលដ្ឋានសកល(GBON) តាមរយៈការស្តារស្ថានីយជាតុអាកាសស្វ័យប្រវត្តិ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្ទុកទិន្នន័យ និងកែលម្អប្រតិបត្តិការនិងការថែទាំ។ គម្រោងមាននូវការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា សម្រាប់មន្ត្រីរបស់ក្រសួងធនធានទឹកនិងឧតុនិយម និងអ្នកបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត។ ការគាំទ្រនេះរួមមានការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ធានាការគ្រប់គ្រងទិន្នន័យប្រកបដោយប្រសិទ្ធភាព និងការបំពាក់ដល់មន្ត្រីនូវជំនាញចាំបាច់ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព។

## ៣- ការបង្កើនការវិនិយោគលើប្រព័ន្ធប្រកាសឱ្យដឹងមុន ដើម្បីពង្រឹងភាពធន់នឹងអាកាសជាតុនិងគ្រោះមហន្តរាយ

*អ្នកផ្តល់ជំនួយ : ធនាគារអភិវឌ្ឍន៍អាស៊ី (មូលនិធិជំនួយបច្ចេកទេសពិសេស); រយៈពេល : ២០២៣-២០២៦; ថវិកា : ៧២៥ 000ដុល្លារ*

គម្រោងថ្នាក់តំបន់នេះ ត្រូវបានអនុវត្តនៅក្នុងប្រទេសចំនួន១០ រួមទាំងប្រទេសកម្ពុជា មានគោលបំណងពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន (EWS) និងបង្កើនការវិនិយោគលើប្រព័ន្ធ EWS នៅទូទាំងប្រទេសសមាជិកកំពុងអភិវឌ្ឍរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ អាទិភាពប្រតិបត្តិការសំខាន់ៗរបស់គម្រោងរួមមានការដោះស្រាយការប្រែប្រួលអាកាសជាតុ ការបង្កើនភាពធន់ទៅនឹងអាកាសជាតុ និងគ្រោះមហន្តរាយ ការកែលម្អអភិបាលកិច្ចនិងសមត្ថភាពស្ថាប័ន និងការជំរុញកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់។

## ៤- គម្រោងកែលម្អសន្តិសុខទឹកនៅកម្ពុជា

*អ្នកផ្តល់ជំនួយ-កម្ចី : ធនាគារពិភពលោក; រយៈពេល : ២០២៤-២០៣០; ថវិកា : ១៤៥លានដុល្លារ; (ប្រហែល៧៥% នៃថវិកាផ្តោតលើប្រព័ន្ធធារាសាស្ត្រ)*

គម្រោងនេះមានគោលបំណងកសាងមូលដ្ឋានគ្រឹះសម្រាប់ការកែលម្អសន្តិសុខទឹកនៅកម្ពុជា និងបង្កើនផលិតភាពកសិកម្ម ក្នុងតំបន់អាងទន្លេមួយចំនួន និងដើម្បីផ្តល់ការឆ្លើយតបភ្លាមៗ និងមានប្រសិទ្ធភាពក្នុងករណីមានវិបត្តិឬគ្រោះអាសន្ន។ សកម្មភាពមួយចំនួនដែលទាក់ទងនឹងការប្រកាសឱ្យដឹងមុន រួមមានការដំឡើងស្ថានីយឧតុនិយមមួយចំនួន និងរៀបចំប្រព័ន្ធប្រកាសឱ្យដឹងមុន សម្រាប់ទឹកជំនន់នៅក្នុងតំបន់។

## ៧.២- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

### ១- សកម្មភាពរួមគ្នាសម្រាប់ការគ្រប់គ្រងគ្រោះថ្នាក់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

*អ្នកផ្តល់ជំនួយ : កម្មវិធីស្បៀងអាហារពិភពលោក; រយៈពេល : ២០២៤-២០២៥; ថវិកា : ១៤២ ០០០ដុល្លារ*

គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពនៅថ្នាក់ជាតិនិងមូលដ្ឋាន ដើម្បីដោះស្រាយផលប៉ះពាល់នៃគ្រោះអាសន្ននិងគ្រោះមហន្តរាយ។ ផ្នែកដែលផ្តោតសំខាន់ៗ រួមមាន (i) ផែនការនិងនីតិវិធីត្រៀមបម្រុង និងឆ្លើយតបគ្រោះមហន្តរាយ, (ii) សកម្មភាពត្រៀមបម្រុងទុកមុន និងប្រព័ន្ធប្រកាសឱ្យដឹងមុន, (iii) ប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ - វេទិកាសម្រាប់ប្រព័ន្ធព័ត៌មានពេលវេលាជាក់ស្តែង (PRISM), (iv) ការសម្របសម្រួលមនុស្សធម៌ និង (v) ការត្រួតពិនិត្យនិងការវាយតម្លៃ។ អ្នកទទួលផលប៉ាន់ស្មាន រួមមានមន្ត្រីគ.ជ.គ.ម. ពីក្រសួងពាក់ព័ន្ធចំនួន៣០នាក់, មន្ត្រីគ.ជ.គ.ម.នៅថ្នាក់ខេត្ត៧៥នាក់, មន្ត្រីគ.ជ.គ.ម. ថ្នាក់ស្រុក១៣២នាក់ (មកពីស្រុកចំនួន៤៤), មន្ត្រីគ.ជ.គ.ម. ថ្នាក់ឃុំចំនួន៣៥២នាក់(ចំនួន៣៥២ឃុំ) និងសមាជិកសហគមន៍ចំនួន៣ ០០០នាក់។

## ៧.៣- ក្រសួងបរិស្ថាន

### ១- គម្រោងគ្រប់គ្រងជម្រកធម្មជាតិសមុទ្រនៅតំបន់សមុទ្រចិនខាងត្បូងនិងឈូងសមុទ្រថៃ

*អ្នកផ្តល់ជំនួយ : មូលនិធិបរិស្ថានសកល; រយៈពេល : ២០២១-២០២៥; ថវិកា : ៥លានដុល្លារ*

គម្រោងថ្នាក់តំបន់មួយនេះអនុវត្តក្នុងប្រទេសចំនួនប្រាំមួយ គឺកម្ពុជា ចិន ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ និងវៀតណាម មានគោលបំណងលើកកម្ពស់ការគ្រប់គ្រង និងអភិរក្សជម្រកធម្មជាតិសមុទ្រ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ សកម្មភាពសំខាន់ៗ រួមមានការវាយតម្លៃអំពីជម្រក ការរៀបចំផែនការគ្រប់គ្រង និងលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាពតាមបណ្តាលសហគមន៍តំបន់ឆ្នេរ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងលើកកម្ពស់ជីវភាពរស់នៅក្នុងតំបន់។ នៅកម្ពុជា គម្រោងនេះត្រូវបានអនុវត្តដោយអគ្គនាយកតំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន និងនាយកដ្ឋានអភិរក្សធនធានជលផល នៃរដ្ឋបាលជលផលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ២- ការបន្សាំនិងភាពធន់ទៅនឹងអាកាសធាតុ នៃសហគមន៍អាស្រ័យលើការនេសាទ នៅតំបន់ឆ្នេរសមុទ្ររបស់កម្ពុជា

*អ្នកផ្តល់ជំនួយ : មូលនិធិអាកាសធាតុបៃតង; រយៈពេល : ២០២១-២០២៥; ថវិកា : ៤,៣៥លានដុល្លារ*

គម្រោងនេះមានគោលបំណងគាំទ្រសហគមន៍ ដែលអាស្រ័យលើការនេសាទតាមឆ្នេរសមុទ្រនៅកម្ពុជាក្នុងការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ គម្រោងនេះផ្តោតលើគោលបំណងសំខាន់ពីរ គឺការពង្រឹងភាពធន់នៃប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ និងការបង្កើនសមត្ថភាពបន្សាំនៃជីវភាពរស់នៅក្នុងតំបន់។ សកម្មភាពសំខាន់ៗ រួមមានការលើកកម្ពស់វិធីសាស្ត្របន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី ដើម្បីកែលម្អសុខភាពនិងនិរន្តរភាពនៃបរិស្ថានតំបន់ឆ្នេរ និងការអនុវត្តបច្ចេកទេសបន្សាំ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ដែលពឹងផ្អែកខ្លាំងលើការនេសាទ។

## ៧.៤- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

### ១- ការកាត់បន្ថយគម្លាតឌីជីថលតាមរយៈការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនិងជំនាញឌីជីថល

*អ្នកអនុវត្ត : ក្រុមហ៊ុន Smart Axiata; រយៈពេល : ២០២៣-២០២៥; ថវិកា : ១៤០ ០០០ដុល្លារ*

គម្រោងនេះមានគោលបំណងបណ្តុះបណ្តាលសិស្សចំនួន៣៨ ៤០០នាក់ និងសាធារណជនលើជំនាញអក្ខរកម្មឌីជីថលនិងឌីជីថល ដោយផ្តោតលើសហគមន៍ក្រីក្រ។ សកម្មភាពសំខាន់ៗរួមមានការគាំទ្រដល់សិស្សានុសិស្សដែលមានពិការភាពចំនួន៧០០នាក់ នៅក្នុងសាលាបឋមសិក្សាចំនួន១៦ នៅទូទាំងរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តសៀមរាប និងផ្តល់ការបណ្តុះបណ្តាលដល់ក្មេងស្រីចំនួន១២០០នាក់ មកពីខេត្តចំនួន១០ តាមរយៈកម្មវិធី Technovation Girls។

### ២- គម្រោងលើកកម្ពស់ការតភ្ជាប់និងនិរន្តរភាព

*អ្នកអនុវត្ត : ក្រុមហ៊ុន Smart Axiata; រយៈពេល : ២០២៣-២០២៥; ថវិកា : ៩០,៧លានដុល្លារ*

គម្រោងនេះផ្តោតលើ : (i) បំពាក់ប៉មចល័តចំនួន២០០ ជាមួយនឹងការប្រើថាមពលពន្លឺព្រះអាទិត្យជាប្រភពបន្ថែម ដើម្បីបង្កើនភាពជឿជាក់សម្រាប់អតិថិជនដែលមានស្រាប់ និង (ii) ដើម្បីបង្កើនការតភ្ជាប់និងកាត់បន្ថយគម្លាតឌីជីថល នៅក្នុងប្រទេស តាមរយៈការសាងសង់ប៉មចល័ត 4G ថ្មីចំនួន៤00 និងប្រព័ន្ធបញ្ជូនគោល (Transmission Backbone) នៅឆ្នាំ២០២៤ និងទីតាំងបន្ថែមចំនួន២00 ផ្សេងទៀតនៅចុងឆ្នាំ២០២៥។

## ៧.៥- កាកបាទក្រហមកម្ពុជា

### ១- គម្រោងភាពធន់ផ្អែកលើសហគមន៍

*អ្នកផ្តល់ជំនួយ : សង្គមកាកបាទក្រហមនៃប្រទេសចិន; រយៈពេល : ២០២៤-២០២៥;*

*ថវិកា : ១៤២ 000ដុល្លារ*

គម្រោងនេះមានគោលបំណងដើម្បីបង្កើនភាពធន់របស់សហគមន៍ ដោយធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះនៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ គម្រោងផ្តោតលើការកែលម្អការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងពង្រីកចំណេះដឹង និងការអនុវត្តផ្នែកសុខភាពនៅកម្រិតសហគមន៍ និងការពង្រឹងសមត្ថភាពរបស់សាខាកាកបាទក្រហមកម្ពុជា នៅខេត្តកំពង់ឆ្នាំង ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ។ លទ្ធផលសំខាន់របស់គម្រោងគឺ (i) ការបង្កើនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការអនុវត្តចំណេះដឹង និងឥរិយាបថផ្នែកសុខភាពរបស់សហគមន៍តាមរយៈការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងកិច្ចអន្តរាគមន៍ផ្នែកសុខភាព

ប្រកបដោយប្រសិទ្ធភាព, (ii) ពង្រឹងសមត្ថភាពរបស់សាខាកាកបាទក្រហមកម្ពុជា ដើម្បីរៀបចំនិងឆ្លើយតបទៅនឹងគ្រោះមហន្តរាយនៅមូលដ្ឋាន រួមទាំងគ្រោះមហន្តរាយសុខភាព ដែលជានាបាននូវការឆ្លើយតបកាន់តែប្រសើរចំពោះគ្រោះមហន្តរាយដែលកើតឡើងម្តងទៀត។

### ២- ការជំរុញសកម្មភាពអាកាសធាតុ និងការប្រកាសឱ្យដឹងមុនចំពោះគ្រោះថ្នាក់ទាក់ទងនឹងអាកាសធាតុនៅក្នុងកាកបាទក្រហមនិងអឌ្ឍចន្ទក្រហមជាតិ (CCA-EWEA)

*អ្នកផ្តល់ជំនួយ : គណៈប្រតិភូចង្កោមប្រទេសនៃ IFRC នៅទីក្រុងបាងកក; រយៈពេល : ២០២៤-២០២៥; ថវិកា : ១០០ ០០០ដុល្លារ*

គម្រោងនេះផ្តោតលើការពង្រីកសកម្មភាពនៃអាកាសធាតុ និងការប្រកាសឱ្យដឹងមុនដែលផ្តោតលើប្រជាជន និងសកម្មភាពដំបូងឬសកម្មភាពត្រៀមបម្រុងទុកមុន សម្រាប់គ្រោះថ្នាក់ទាក់ទងនឹងអាកាសធាតុ។ គោលបំណង គឺកសាងសមត្ថភាពរបស់មន្ត្រីកាកបាទក្រហមកម្ពុជាចំនួន៦០នាក់ និងអ្នកស្ម័គ្រចិត្ត លើសកម្មភាពអាកាសធាតុ ការត្រៀមបម្រុង និងប្រព័ន្ធប្រកាសអាសន្ននៅសហគមន៍ ដោយផ្តោតលើការត្រៀមបម្រុងសម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ការវាយតម្លៃភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំប្រសើរឡើង និងប្រព័ន្ធប្រកាសអាសន្ននៅសហគមន៍។

## ៧.៦- ស្ថាប័ននៃអង្គការសហប្រជាជាតិនិងគម្រោងពហុភាគី

### ១- គម្រោងពហុប្រទេសដើម្បីជំរុញការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា

*អ្នកផ្តល់ជំនួយ : មូលនិធិអាកាសធាតុបៃតង; រយៈពេល : ២០២៥-២០៣០; ថវិកា : ១៣,៥លានដុល្លារ*

គោលបំណងរួមគម្រោងនេះ ដើម្បីផ្តល់នូវប្រព័ន្ធប្រកាសឱ្យដឹងមុនចំពោះពហុគ្រោះថ្នាក់ (MHEWS) ដែលដំណើរការរួមទាំងសកម្មភាពត្រៀមបម្រុងទុកមុន ដោយផ្តោតលើគម្លាតសំខាន់ៗដែលរារាំងដល់ប្រសិទ្ធភាព និងភាពរលូននៃខ្សែចង្វាក់តម្លៃរបស់ប្រព័ន្ធប្រកាសឱ្យដឹងមុនចំពោះពហុគ្រោះថ្នាក់។ ដៃគូប្រតិបត្តិសំខាន់ៗរបស់គម្រោង រួមមានគ.ជ.គ.ម. ក្រសួងធនធានទឹកនិងឧតុនិយម កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការភីផលអិននិត។

### ២- ភាពជាដៃគូរវាងរដ្ឋ សហគមន៍ និងវិស័យឯកជន ដើម្បីកសិកម្មមានភាពរភាពបរិស្ថាន និងជីវភាពប្រជាជនមានភាពធន់ នៅភាគខាងជើងបឹងទន្លេសាប (គម្រោង PEAL)

*អ្នកផ្តល់ជំនួយ : មូលនិធិអាកាសធាតុបៃតង; គ្រប់គ្រងដោយ : អង្គការស្បៀង និងកសិកម្ម; រយៈពេល : ២០២៣-២០២៩; ថវិកា : ៤២,៩លានដុល្លារ*

គម្រោងនេះមានគោលបំណងបង្កើនភាពធន់នឹងអាកាសធាតុរបស់កសិករខ្នាតតូច និងសហគមន៍មូលដ្ឋាន។ តាមរយៈគម្រោងនេះ គេរំពឹងថានឹងបានផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនចំនួន៤៥០ពាន់នាក់ នៅក្នុងខេត្តចំនួនបួន(ឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ និងសៀមរាប) និងសហគមន៍កសិកម្មចំនួន១២៤។ សមាសធាតុពាក់ព័ន្ធសំខាន់ៗរបស់គម្រោង គឺការកែលម្អសេវាកម្មកសិកម្មដែលស្របតាមខ្សែចង្វាក់តម្លៃជាក់លាក់នៃដំណាំនៅខេត្តគោលដៅ។ គម្រោងនេះមានការសហប្រតិបត្តិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និងមានការចូលរួមពីក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងកិច្ចការនារី និងធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ។ ក្រសួងធនធានទឹកនិងឧតុនិយម ជាដៃគូអនុវត្តដែលដឹកនាំសកម្មភាពទាក់ទង

និងការពង្រឹងការព្យាករនៃកសិ-ឧតុនិយម ជាមួយការរៀបចំស្ថានីយឧតុនិយមស្វ័យប្រវត្តិថ្មី ចំនួន៨ និងជួសជុលស្ថានីយដែលមានស្រាប់ នៅក្នុងខេត្តគោលដៅរបស់គម្រោង។

**៣- ការលើកកម្ពស់ជីវភាពរស់នៅដែលធន់នឹងអាកាសធាតុ របស់សហគមន៍អាស្រ័យនឹងដំណាំស្រូវនៅតំបន់ទន្លេសាប**

*អ្នកផ្តល់ជំនួយ : មូលនិធិបរិស្ថានសកល; គ្រប់គ្រងដោយ : អង្គការស្បៀងនិងកសិកម្ម; រយៈពេល : ២០២២-២០២៧; ថវិកា : ៨,៩លានដុល្លារ*

គម្រោងមានគោលបំណងកាត់បន្ថយភាពងាយរងគ្រោះនៃអាកាសធាតុរបស់ប្រជាជន និងបង្កើនភាពធន់របស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈអភិក្រមផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងទីផ្សារ។ គម្រោងនេះត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកសហគមន៍មូលដ្ឋានរបស់ក្រសួងបរិស្ថាន អនុវត្តនៅក្នុងខេត្តគោលដៅចំនួនប្រាំនៅជុំវិញបឹងទន្លេសាប គឺខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។

**៤- ការពង្រឹងការគ្រប់គ្រងទឹកចម្រុះនិងភាពធន់ទៅនឹងអាកាសធាតុ នៅក្នុងតំបន់ទីក្រុងដែលងាយរងគ្រោះនៃតំបន់អាងទន្លេមេគង្គ**

*អ្នកផ្តល់ជំនួយ : ក្រសួងបរិស្ថាននៃសាធារណរដ្ឋកូរ៉េ; គ្រប់គ្រងដោយ : អង្គការស្បៀងនិងកសិកម្ម; រយៈពេល : ២០២១-២០២៥; ថវិកា : ១,៦លានដុល្លារ*

គម្រោងនេះមានគោលបំណងពង្រឹងភាពធន់របស់ប្រជាជន និងសហគមន៍នៅក្នុងតំបន់ងាយរងគ្រោះដោយអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជានិងឡាវ។ គម្រោងផ្តោតលើ : (i)ការបញ្ចប់ការវាយតម្លៃហានិភ័យអាកាសធាតុទាក់ទងនឹងទឹកប្រកបដោយបរិយាបន្ន នៅក្នុងតំបន់អាងទន្លេអាទិភាព, (ii)ការពង្រឹងបរិស្ថានអំណោយផលសម្រាប់ការឆ្លើយតបទាក់ទងនឹងយេនឌ័រ, ការផ្តល់ព័ត៌មានអំពីហានិភ័យនៃអាកាសធាតុ និងការគ្រប់គ្រងធនធានទឹកចម្រុះ និង (iii)ការអភិវឌ្ឍគម្រោងសំណើសុំមូលនិធិសម្រាប់វិធានការកាត់បន្ថយហានិភ័យអាទិភាព។ ដៃគូអនុវត្តសំខាន់ៗរួមមានក្រសួងធនធានទឹកនិងឧតុនិយម គ.ជ.គ.ម. និងលេខាធិការដ្ឋាននៃគ.ជ.អ.ប.។ ទីតាំងគម្រោងនៅកម្ពុជា គឺនៅក្នុងតំបន់អាងនៃព្រែកចំនួនបួន រួមមានព្រែកប្រស់ ព្រែកគ្រៀង ព្រែកកាំពី និងព្រែកតេ និងទន្លេចំនួនបីផ្សេងទៀតគឺ ទន្លេសេកុង សេសាន្ត និងស្រែពក។

**៥- ការពង្រឹងភាពធន់នឹងអាកាសធាតុនៅក្នុងអនុតំបន់មេគង្គ**

*អ្នកផ្តល់ជំនួយ : DFAT; គ្រប់គ្រងដោយ : អង្គការ Oxfam កម្ពុជា; រយៈពេល : ២០២២-២០២៥; ថវិកា: ៦០០ ០០០ដុល្លារ*

គម្រោងនេះមានគោលបំណងបង្កើនភាពធន់នៅក្នុងសហគមន៍តាមទន្លេមេគង្គ។ គម្រោងបង្កើតឡើងនៅលើកិច្ចខិតខំផ្អែកអភិបាលកិច្ចឆ្លងដែនរបស់អង្គការ Oxfam ដោយផ្តោតលើបរិយាបន្នសង្គម។ គោលដៅចម្បងរបស់គម្រោង គឺដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយសម្រាប់សហគមន៍តាមដងទន្លេនៃអនុតំបន់មេគង្គ កាត់បន្ថយផលប៉ះពាល់

នៃការប្រែប្រួលអាកាសធាតុ តាមរយៈអភិបាលកិច្ចកាន់តែប្រសើរ យុទ្ធសាស្ត្របន្សាំដែលជំរុញដោយសហគមន៍ និងការបង្កើនកិច្ចសហប្រតិបត្តិការឆ្លងដែន។

## ៦- ការចិញ្ចឹមបីបាច់ : ការចិញ្ចឹមបីបាច់ឱ្យមានភាពធន់ទៅនឹងអាកាសធាតុនៅកម្ពុជា

*អ្នកផ្តល់ជំនួយ : ទីភ្នាក់ងារស៊ុីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ; រយៈពេល : ២០២២-២០២៦; ថវិកា : ៤,៧លានដុល្លារ*

គម្រោងនេះមានគោលបំណងលើកកម្ពស់ភាពធន់ទៅនឹងអាកាសធាតុ និងបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារកសិករខ្នាតតូចដែលងាយរងគ្រោះ តាមរយៈប្រព័ន្ធកសិ-អេកូឡូស៊ីដែលធន់នឹងអាកាសធាតុ។ គម្រោងផ្តោតលើ កសិករខ្នាតតូចចំនួន១៥ 000គ្រួសារ នៅក្នុងឃុំចំនួន៣៦ នៃស្រុកចំនួន១២ ក្នុងខេត្តគោលដៅចំនួន៤ ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានប្រព័ន្ធជាវាសាស្ត្រ គណនេយ្យភាពសង្គម និងការទទួលយកការអនុវត្តបច្ចេកទេសកសិ-អេកូឡូស៊ី។ ដៃគូប្រតិបត្តិសំខាន់របស់គម្រោង គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៧- ការពង្រឹងកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាស៊ាន

*អ្នកផ្តល់ជំនួយ និងគ្រប់គ្រងដោយ : ធនាគារអភិវឌ្ឍន៍អាស៊ី; រយៈពេល : ២០២១-២០២៥; ថវិកា : ១,៩ លានដុល្លារ*

គម្រោងនេះជួយដល់រដ្ឋសមាជិកអាស៊ានក្នុងការអនុវត្តកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបបន្ទាន់ ដោយផ្តោតលើការបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់ ការណែនាំបច្ចេកវិទ្យាទំនើបសម្រាប់ការគ្រប់គ្រងហានិភ័យឆ្លងដែន និងការជំរុញកិច្ចសហប្រតិបត្តិការអន្តរតំបន់តាមរយៈការកសាងសមត្ថភាព និងការផ្លាស់ប្តូរចំណេះដឹង។ សកម្មភាពសំខាន់ផ្តោតលើ : (i) បង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់លើហានិភ័យឆ្លងដែន, (ii) ការណែនាំអំពីបច្ចេកវិទ្យាទំនើបដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើហានិភ័យទាំងនេះ និង (iii) ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរតំបន់តាមរយៈការកសាងសមត្ថភាពនិងការផ្លាស់ប្តូរចំណេះដឹង។

## ៨- លើកកម្ពស់ប្រព័ន្ធប្រកាសឱ្យដឹងមុននៅកម្ពុជា

*អ្នកផ្តល់ជំនួយ : GSMA & UK AID; គ្រប់គ្រងដោយ : អង្គការ ActionAid ; រយៈពេល : ២០២៣-២០២៥; ថវិកា : ៤៤៣ 000ដុល្លារ*

គម្រោងនេះមានគោលបំណងពង្រឹងសកម្មភាពត្រៀមទុកមុននៃមនុស្សធម៌ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវឧបករណ៍ចាប់សញ្ញាត្រួតពិនិត្យកម្រិតទឹកក្រោមដី ដើម្បីបញ្ជូនទិន្នន័យកម្ពស់ទឹកតាមពេលវេលាជាក់ស្តែង ទៅកាន់ប្រព័ន្ធប្រកាសឱ្យដឹងមុនថ្នាក់ជាតិរបស់កម្ពុជា។ គម្រោងនេះព្យាយាមពង្រឹងប្រព័ន្ធ EWS1294 ដោយពង្រីកការគ្របដណ្តប់របស់ខ្លួនទៅកាន់ខេត្តថ្មីដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យ កសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធជានាឱ្យក្រុមដែលងាយរងគ្រោះអាចទទួលបានព័ត៌មានទាន់ហេតុការណ៍ និងជំរុញការសម្របសម្រួលជាទៀងទាត់ ក្នុងចំណោមក្រសួង ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការមិនមែនរដ្ឋាភិបាល។ ដៃគូអនុវត្តសំខាន់គឺ ក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## ៨- ការគ្រប់គ្រងហានិភ័យ

ការអនុវត្តប្រកបដោយជោគជ័យនៃផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា (EW4All) ត្រូវការយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យដ៏រឹងមាំ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលអាចរារាំងដល់វឌ្ឍនភាពនៃសកម្មភាព។

1. ហានិភ័យចម្បងមួយគឺការសម្របសម្រួលក្នុងចំណោមក្រសួងនិងស្ថាប័នផ្សេងៗ។ ដើម្បីកាត់បន្ថយបញ្ហានេះ ការរៀបចំនិងអនុវត្តយន្តការសម្របសម្រួលដែលដឹកនាំដោយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅចំណុច(៦.១)មានសារៈសំខាន់ណាស់។ យន្តការនេះនឹងជំរុញកិច្ចសហការ និងការប្រាស្រ័យទាក់ទងគ្នារវាងភាគីពាក់ព័ន្ធ ដោយធានាថាតួនាទី និងការទទួលខុសត្រូវត្រូវបានអនុវត្ត និងកំណត់យ៉ាងច្បាស់លាស់។ ការប្រជុំប្រចាំត្រីមាស/ឆមាសជាទៀងទាត់នឹងផ្តល់នូវវេទិកាមួយសម្រាប់ដោះស្រាយបញ្ហាភ្លាមៗ ដែលអនុញ្ញាតឱ្យមានការគ្រប់គ្រងសម្របសម្រួលការអនុវត្តសកម្មភាពផែនទីបង្ហាញផ្លូវ។
2. ហានិភ័យដ៏សំខាន់មួយទៀតគឺសក្តានុពលសម្រាប់ការចែករំលែកទិន្នន័យមិនគ្រប់គ្រាន់ និងលទ្ធភាពទទួលបានពីប្រភពផ្សេងៗគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ ប្រព័ន្ធគ្រប់គ្រងទិន្នន័យកណ្តាល (សម្រាប់ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ) គួរតែត្រូវបានបង្កើតឡើង ដែលអនុញ្ញាតឱ្យមានការផ្លាស់ប្តូរព័ត៌មានក្នុងពេលជាក់ស្តែងក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដោយផ្សារភ្ជាប់វគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកមកពីក្រសួងនិងស្ថាប័នពាក់ព័ន្ធនឹងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់ប្រព័ន្ធនេះឱ្យមានប្រសិទ្ធភាព។
3. ឧបសគ្គផ្នែកហិរញ្ញវត្ថុក៏អាចបង្កហានិភ័យដល់ការអនុវត្តផែនទីបង្ហាញផ្លូវផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះ ការធានាបាននូវមូលនិធិពីប្រភពជាច្រើន រួមទាំងដៃគូអភិវឌ្ឍអន្តរជាតិ និងការរួមចំណែកពីវិស័យឯកជន នឹងមានសារៈសំខាន់ណាស់។ ការបង្កើតផែនការថវិកា និងហិរញ្ញវត្ថុច្បាស់លាស់ ដែលបង្ហាញពីតម្រូវការមូលនិធិសម្រាប់សសរស្តម្ភនីមួយៗ នឹងជួយក្នុងការទាក់ទាញការវិនិយោគ និងធានានូវការគាំទ្រផ្នែកហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ ជាងនេះទៅទៀត ការត្រួតពិនិត្យហិរញ្ញវត្ថុតាមកាលកំណត់នឹងជួយក្នុងការកំណត់អត្តសញ្ញាណគម្លាតនៃមូលនិធិ និងការបែងចែកធនធានតាមការចាំបាច់។
4. ការចូលរួមពីសហគមន៍គឺមានសារៈសំខាន់សម្រាប់ភាពជោគជ័យនៃគំនិតផ្តួចផ្តើម EW4All ។ ហានិភ័យកើតមាន ប្រសិនបើសហគមន៍មូលដ្ឋានមិនត្រូវបានជូនដំណឹងឱ្យបានគ្រប់គ្រាន់ ឬពាក់ព័ន្ធនឹងប្រព័ន្ធប្រកាសឱ្យដឹងមុន។ ដើម្បីកាត់បន្ថយបញ្ហានេះ កម្មវិធីផ្សព្វផ្សាយគោលដៅគួរតែត្រូវបានបង្កើតឡើង ដើម្បីអប់រំសហគមន៍អំពីសារៈសំខាន់នៃប្រព័ន្ធប្រកាសឱ្យដឹងមុន និងរបៀបដែលពួកគេអាចចូលរួម។ ការចូលរួមជាមួយអ្នកដឹកនាំក្នុងកម្រិតមូលដ្ឋាន និងការប្រើប្រាស់

ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក អាចបង្កើនការយល់ដឹងនិងជំរុញវប្បធម៌នៃការត្រៀមខ្លួន ដោយធានាថាសហគមន៍មានភាពធន់នឹងការប្រឈមមុខនឹងគ្រោះមហន្តរាយ។

## ៩- សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក "ផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា" តំណាងឱ្យជំហានដ៏សំខាន់មួយឆ្ពោះទៅរកការបង្កើនការត្រៀមខ្លួន និងការឆ្លើយតបគ្រោះមហន្តរាយក្នុងការប្រឈមនឹងការកើនឡើងនៃការគំរាមកំហែងអំពីមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ផែនទីបង្ហាញផ្លូវនេះបង្កើតឡើងដោយមានការគាំទ្រ ពីអង្គការសហប្រជាជាតិ និងដៃគូជាតិនិងអន្តរជាតិសំខាន់ៗ ក្នុងគោលបំណងបង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុនដ៏រឹងមាំមួយ ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះដោយគ្រោះមហន្តរាយនៅកម្ពុជា។

កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន កាកបាទក្រហមកម្ពុជា បានសហការរៀបចំផែនទីបង្ហាញផ្លូវនេះ ដើម្បីធានាថាគំនិតផ្តួចផ្តើមស្តីពីការប្រកាសឱ្យដឹងមុនសម្រាប់ទាំងអស់គ្នា មិនត្រឹមតែអាចអនុវត្តបានជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លើយតបទៅនឹងស្ថានភាពនានាដែលកើតមាននៅមូលដ្ឋានផងដែរ។

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនទីបង្ហាញផ្លូវនេះ យើងត្រូវអនុវត្តយន្តការស្របសម្រួលរួមគ្នាប្រកបដោយប្រសិទ្ធភាព ការចែករំលែកទិន្នន័យ ផែនការហិរញ្ញវត្ថុ និងការចូលរួមរបស់សហគមន៍។ រួមជាមួយនឹងការប្តេជ្ញាចិត្តរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ យើងអាចពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់យើង ដោយធានាបាននូវព័ត៌មានទាន់ពេលវេលានិងត្រឹមត្រូវ ដែលនឹងអាចកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ និងកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយសម្រាប់ប្រទេសកម្ពុជា។

## ផែនការសកម្មភាពនៃផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការពង្រីកប្រព័ន្ធប្រកាសឱ្យដឹងមុន

| **សសរស្តម្ភទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ** | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង : ពង្រឹងការធ្វើផែនទីគ្រោះថ្នាក់ ការប៉ះពាល់ និងភាពងាយរងគ្រោះ និងការវាយតម្លៃហានិភ័យចំពោះពហុគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងរលកកម្តៅ ដោយយកប្រជាជនជាគោល ជាពិសេសអ្នកងាយរងគ្រោះបំផុត រួមមានស្ត្រី កុមារ មនុស្សចាស់ អ្នកមានពិការភាព និងសហគមន៍ខ្វះខាត។ | | | | | | | | | | | |
| គោលនយោបាយនិងអាទិភាពរបស់រដ្ឋាភិបាលពាក់ព័ន្ធ : ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០២៤-២០២៨; ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣; ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងគោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន | | | | | | | | | | | |
| គម្លាត | លទ្ធផលរំពឹងទុក | សូចនាករលទ្ធផល | សកម្មភាព | អ្នកទទួលខុសត្រូវ | | ពេលវេលាអនុវត្តន៍ (ឆ្នាំ) | | | | ថវិកា (ដុល្លារ) | ប្រភពថវិកា |
| | | | | ដឹកនាំ | គាំទ្រ | ទី១ | ទី២ | ទី៣ | ទី៤ | | |
| លទ្ធផលកម្រិតមធ្យម ១.១ : បង្កើនសមត្ថភាពផលិតព័ត៌មានប្រកបដោយគុណភាព ទាន់ពេលវេលា និងត្រូវបរិបទនៃហានិភ័យ និងគ្រោះមហន្តរាយ (ការបាត់បង់និងការខូចខាត) តាមរយៈអភិក្រមដោយមានការចូលរួម និងបរិយាបន្ន | | | | | | | | | | | |
| **១.១.១ ទិន្នន័យការបាត់បង់ និងការខូចខាតពីគ្រោះមហន្តរាយមិនត្រូវបានប្រមូល និងកត់ត្រាជាប្រព័ន្ធពិសេសទាក់ទងនឹងយេនឌ័រ អាយុ ពិការភាព និងភាពងាយរងគ្រោះក្នុងសង្គមផ្សេងទៀត។** | ១.១.១ ការវិភាគហានិភ័យគ្រោះមហន្តរាយ និងសមត្ថភាពចំណេះដឹងអំពីហានិភ័យស្ទួលសម្រាប់ប្រកាសឱ្យដឹងមុន ត្រូវបានពង្រឹងជាមួយនឹងទិន្នន័យដែលបែងចែកតាមភេទ អាយុ ពិការភាព និងភាពងាយរងគ្រោះក្នុងសង្គមផ្សេងទៀត។ | ប្រព័ន្ធព័ត៌មានការបាត់បង់និងការខូចខាតជាតិដែលបានកែលម្អ មានដំណើរការ និងបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយជាតិជាមួយនឹងយន្តការប្រមូលទិន្នន័យដែលមានការញែក (ឧ. ភេទ អាយុ ពិការភាព) ចំនួនឧបករណ៍ និងវិធីសាស្ត្រប៉ាន់ស្មានលើការបាត់បង់ និងការខូចខាត។ | ១.១.១.១ ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបាត់បង់ និងការខូចខាតជាតិ (CamDi) ដើម្បីបើកឱ្យមានរបាយការណ៍ដែលបែងចែកតាមភេទ អាយុ ពិការភាព និងភាពងាយរងគ្រោះក្នុងសង្គម ទៅកាន់ប្រព័ន្ធទិន្នន័យការបាត់បង់ និងការខូចខាតសកល | NCDM | UNDRR<br>UNDP<br>WFP<br>GS-NSPC<br>FAO<br>IFRC/CRC<br>IOM<br>MPTC | X | x | x | x | ៦៥០ 000 | CREWS<br>UNDP-GCF |
| | | | ១.១.១.២ បង្កើតវិធីសាស្ត្រសម្រាប់កំណត់បរិមាណការបាត់បង់ និងការខូចខាតក្នុងន័យរូបវន្ត និងសេដ្ឋកិច្ច សម្រាប់ទ្រព្យសកម្មសេដ្ឋកិច្ចសំខាន់ៗដែលទទួលស្គាល់ដោយក្រសួង ស្ថាប័នរដ្ឋាភិបាលសំខាន់ៗ | | | | | | | ៣៥០ 000 | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួននៃការធ្វើបច្ចុប្បន្នភាពមានលក្ខណៈច្នៃប្រឌិតរួមបញ្ចូលទៅក្នុងប្រព័ន្ធ PRISM ដែលបង្កើនសមត្ថភាពវិភាគហានិភ័យអាកាសធាតុរបស់ជាតិ | ១.១.១.៣ សាកល្បងបច្ចេកវិទ្យា និងការច្នៃប្រឌិតថ្មីសម្រាប់ការបង្កើតចំណេះដឹងអំពីហានិភ័យតាមរយៈ PRISM, CamDi និងឧបករណ៍ពាក់ព័ន្ធផ្សេងទៀត | | | | | | | ៦២០ ០០០ | |
| | | | ១.១.១.៤ កសាងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលក្នុងការប្រមូល វិភាគ និងរាយការណ៍ទិន្នន័យជាលក្ខណៈប្រព័ន្ធស្ដីពីការបាត់បង់ និងការខូចខាតដោយគ្រោះមហន្តរាយដោយបែងចែកភេទ អាយុ និងពិការភាព | | | | | | | ២៥០ ០០០ | |
| | | | ១.១.១.៥ ផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដល់ភាគីពាក់ព័ន្ធថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីវាយតម្លៃហានិភ័យនៅកម្រិតសហគមន៍ រួមទាំងការកំណត់អត្តសញ្ញាណហានិភ័យ និងគ្រោះថ្នាក់ ភាពងាយរងគ្រោះ ការធ្វើផែនទីភាពប្រឈមនិងសមត្ថភាពបន្សាំ ដោយរួមបញ្ចូលនូវអភិក្រមប្រកបដោយបរិយាបន្នសង្គម និងយេនឌ័រ ដោយប្រើឧបករណ៍ និងវិធីសាស្ត្រដែលមានស្រាប់ ( ឧ. EVCA ) | | | | | | | ៣៥០ ០០០ | |
| | | | ១.១.១.៦ ធ្វើការវាយតម្លៃហានិភ័យសហគមន៍នៅក្នុងតំបន់គោលដៅ ដោយផ្តោតលើការប្រមូល និងបញ្ចូលទិន្នន័យស្តីពីប្រជាជនងាយរងគ្រោះ រួមទាំងស្ត្រី កុមារ មនុស្សចាស់ និងអ្នកមានពិការភាព ដើម្បីបំពេញបន្ថែមទិន្នន័យ និងព័ត៌មានដែលប្រមូលបានតាមរយៈផែនទីហានិភ័យផ្សេងទៀត | | | | | | | ៣៧៥ ០០០ | |
| | | | ១.១.១.៧ បង្កើតពិធីសារចែករំលែកទិន្នន័យ និងគោលការណ៍ណែនាំសម្រាប់ | | | | | | | ៤៥០ ០០០ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ការផ្លាស់ប្តូរទិន្នន័យប្រកបដោយសុវត្ថិភាព និងសីលធម៌ ដោយរួមប្រព័ន្ធគ្រប់គ្រងទិន្នន័យជាតិដែលមានស្រាប់ (CamDi, PRISM, អត្តសញ្ញាណគ្រួសារក្រីក្រ និងថ្នាលចុះបញ្ជីគាំពារសង្គម ។ល។) | | | | | | | | |
| **១.១.២ មិនមានសារពើភណ្ឌ ឬប្រព័ន្ធទិន្នន័យជាតិ អំពីភាពប្រឈមជាក់លាក់ចំពោះចំនួនប្រជាជន ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សេវាកម្ម និងទ្រព្យធន ដែលបែងចែកតាមភេទ អាយុ និងពិការភាព** | ១.១.២ មានសារពើភណ្ឌជាតិដែលមានសំណុំទិន្នន័យនៃការប៉ះពាល់ពីវិស័យពាក់ព័ន្ធ រួមទាំងទិន្នន័យដែលបានបែងចែកតាមភេទ អាយុ ពិការភាព និងភាពងាយរងគ្រោះក្នុងសង្គម | ចំនួនសំណុំទិន្នន័យអំពីភាពប្រឈមសំខាន់ៗតាមវិស័យ រួមជាមួយព័ត៌មានទីតាំង បែងចែកតាមភេទ អាយុ ពិការភាព និងភាពងាយរងគ្រោះក្នុងសង្គម | ១.១.២.១ គូសផែនទីសំណុំទិន្នន័យដែលមានស្រាប់អំពីភាពប្រឈមរបស់ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងទ្រព្យធនដែលមាននៅក្រសួង និង/ឬអង្គការដៃគូនានា ដោយធានាឱ្យមានការរួមបញ្ចូលនូវទិន្នន័យភាពងាយរងគ្រោះសង្គមដែលបែងចែកតាម ភេទ អាយុ និងពិការភាព | NCDM | UNDRR<br>MoRD<br>MAFF<br>MoP,<br>NCDDS<br>MoE<br>WFP<br>UNDP<br>IOM<br>MPTC | X | x | | | ២៦៥ ០០០ | UNDP-GCF |
| | | | ១.១.២.២ បង្កើតឱ្យមានការប្រមូលទិន្នន័យជាតិ យន្តការឬការរៀបចំការចែករំលែក និងការធានាគុណភាពទិន្នន័យ (ការគ្រោះថ្នាក់ ភាពប្រឈម ភាពងាយរងគ្រោះ) និង ព័ត៌មានអំពីទិន្នន័យដែលមានស្តង់ដា | | | | | | | ១៩០ ០០០ | |
| **១.១.៣ ការវាយតម្លៃហានិភ័យគ្រោះមហន្តរាយ ការកំណត់ទម្រង់ភាពងាយរងគ្រោះ ទិន្នន័យផលប៉ះពាល់ក្នុងអតីតកាល មិនត្រូវបានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ** | ១.១.៣ ផែនការសង្គ្រោះបន្ទាន់ថ្នាក់ជាតិ/ខេត្ត របស់ គ.ជ.គ.ម. និងដំណើរការត្រៀមបម្រុង និងឆ្លើយតបក្នុងគ្រាអាសន្ន ជាមួយនឹងការវាយតម្លៃគ្រោះថ្នាក់ ការប៉ះពាល់ និងភាពងាយរងគ្រោះរួមបញ្ចូលគ្នា ត្រូវបានជូនដំណឹងដោយទិន្នន័យផលប៉ះពាល់ | ចំនួននៃផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានរៀបចំឡើងផ្អែកលើព័ត៌មានភាពងាយរងគ្រោះ និងការវាយតម្លៃហានិភ័យដែលបានធ្វើបច្ចុប្បន្នភាព | ១.១.៣.១ គាំទ្រដល់ការបង្កើតពិធីសារវាយតម្លៃហានិភ័យថ្នាក់ជាតិដែលប្រកបដោយស្តង់ដា និងឧបករណ៍ដែលអនុលោមតាមបរិបទប្រទេស និងមូលដ្ឋាន | NCDM | UNDRR<br>WFP<br>UNDP<br>MoE<br>MoP<br>NCDDS<br>MoWRAM<br>IOM | x | x | | | ២៥០ ០០០ | មិនទាន់មានប្រភព |
| | | | ១.១.៣.២ ដាក់បញ្ចូលការវាយតម្លៃហានិភ័យទៅក្នុងផែនការត្រៀមបម្រុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងតម្រូវការចំណាយសម្រាប់ការធ្វើបច្ចុប្បន្នភាពតាមកាលកំណត់ និងគាំទ្រការកសាងសមត្ថភាពដែលពាក់ព័ន្ធ ដោយធានាថាការវាយតម្លៃទាំងនេះមានបរិយាបន្នសង្គម និងយេនឌ័រ | | | | | | | ៣៥០ ០០០ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | កន្លងមក (កិច្ចបាត់បង់ និងខូចខាត) | | | | | | | | | | |
| **១.១.៤ អត្ថមាននៃវិធីសាស្ត្រវាយតម្លៃតម្រូវការក្រោយព្រឹត្តិការណ៍គ្រោះមហន្តរាយ (PDNA) សម្រាប់ប្រើប្រាស់បានងាយស្រួល គ្របដណ្តប់លើវិស័យដែលរងផលប៉ះពាល់ដោយព្រឹត្តិការណ៍គ្រោះថ្នាក់ជាទូទៅ** | ១.១.៤ ដំណើរការវាយតម្លៃតម្រូវការក្រោយព្រឹត្តិការណ៍គ្រោះមហន្តរាយ (PDNA) ត្រូវបានបង្កើតឡើង និងបញ្ចូលនៅក្នុងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយជាតិ ដើម្បីជួយសម្រួលដល់ការវាយតម្លៃទាន់ពេលវេលាលើផលប៉ះពាល់គ្រោះថ្នាក់ និងជូនដំណឹងដល់កិច្ចខិតខំសង្គ្រោះទាន់ពេល | វិធីសាស្ត្រវាយតម្លៃតម្រូវការក្រោយព្រឹត្តិការណ៍គ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់ដោយភ្នាក់ងារតាមវិស័យសំខាន់ៗ | ១.១.៤.១ ធ្វើផែនទីតម្រូវការតាមវិស័យអាទិភាព និងធាតុចូលទិន្នន័យដែលត្រូវប្រមូលបន្ទាប់ពីព្រឹត្តិការណ៍គ្រោះថ្នាក់ សម្រាប់បំពេញបន្ថែមទៅនឹងការប្រមូលទិន្នន័យអំពីកិច្ចបាត់បង់និងខូចខាត | NCDM | UNDRR<br>WFP<br>UNDP<br>MoE<br>MoWRAM<br>MAFF<br>GS-NSPC<br>CRC<br>MoWA<br>MoP<br>IOM<br>MPTC | x | x | x | | ១៨០ ០០០ | មិនទាន់មានប្រភពថវិកា |
| | | | ១.១.៤.២ រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដា (SOP) លំហូរការងារអន្តរភ្នាក់ងារ និងឧបករណ៍ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យមានការធ្វើ PDNA ប្រកបដោយប្រសិទ្ធភាពតាមស្ថានភាពភូមិសាស្ត្រផ្សេងគ្នា ប្រកបព្រមដោយបរិយាបន្នសង្គម និងយេនឌ័រ ដើម្បីធានាថាតម្រូវការរបស់ប្រជាជនដែលរងផលប៉ះពាល់ទាំងអស់ ត្រូវបានដោះស្រាយ | | | | | | | ២៧៥ ០០០ | |
| | | | ១.១.៤.៣ ដាក់បញ្ចូលការធ្វើ PDNA ទៅក្នុងផែនការត្រៀមបម្រុងសង្គ្រោះបន្ទាន់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់គ.ជ.ក.ម. រួមទាំងមានការបែងចែកថវិកា និងការកសាងសមត្ថភាពបានគ្រប់គ្រាន់ | | | | | | | ៣៨០ ០០០ | |
| **១.១.៥ ការបង្កើតចំណេះដឹងតាមរយៈការស្រាវជ្រាវចំគោលដៅទាក់ទងនឹងហានិភ័យគ្រោះថ្នាក់នៅក្នុង** | ១.១.៥ មានផលិតផលចំណេះដឹងថ្មីៗអំពីហានិភ័យដែលជំរុញដល់ការយល់ដឹងឱ្យកាន់តែច្បាស់អំពីហានិភ័យពហុគ្រោះថ្នាក់ អាចប្រើប្រាស់បាន | ចំនួនផែនទីគ្រោះថ្នាក់ជាក់លាក់ និង/ឬ ម៉ូដែលនៃផលប៉ះពាល់ | ១.១.៥.១ គាំទ្រដល់ការស្រាវជ្រាវ និងបង្កើតកស្តុតាង ដើម្បីបង្កើនចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ នៅក្នុងប្រទេសកម្ពុជា តាមរយៈការវិភាគជាប្រព័ន្ធលើទិន្នន័យដែលប្រមូលបានពី CamDi, PRISM និងសំណុំទិន្នន័យដទៃទៀត | NCDM | MoWRAM<br>UNDRR<br>WMO<br>UNDP<br>WFP | x | x | | | ៣៥០ ០០០ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសកម្ពុជា នៅមានកម្រិត | សម្រាប់អ្នកធ្វើការសម្រេចចិត្ត | | ១.១.៥.២ បង្កើតផែនទីហានិភ័យពហុគ្រោះថ្នាក់តាមតម្រូវការ និងម៉ូដែលនៃផលប៉ះពាល់ ដែលមានបរិយាបន្នសង្គម និងយេនឌ័រ ជានាថាឧបករណ៍ទាំងនេះឆ្លុះបញ្ចាំងពីផលប៉ះពាល់ខុសគ្នា តាមក្រុមប្រជាជនផ្សេងគ្នា ដូចជាក្រុមស្ត្រី កុមារ ចាស់ជរា និងជនមានពិការភាព | | IFRC<br>IOM<br>MPTC | | | | | ៤៨០ ០០០ | |
| **លទ្ធផលកម្រិតមធ្យម ១.២ : លទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានព័ត៌មានហានិភ័យ និងចំណេះដឹងដោយតួអង្គពាក់ព័ន្ធទាំងអស់** | | | | | | | | | | | |
| **១.២.១ អន្តរប្រតិបត្តិការនៅមានកម្រិតចំពោះការគ្រប់គ្រងធនធានទឹក, គ្រោះមហន្តរាយសកម្ម និងថ្នាលចុះបញ្ជីគាំពារសង្គម** | ១.២.១ ការចែករំលែកទិន្នន័យមានភាពប្រសើរឡើង និងដោយស្វ័យប្រវត្តិរវាងវេទិកាសំខាន់ៗ ដែលប្រើសម្រាប់ការប្រមូលទិន្នន័យដែលមានការព្រែកពីហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងធនធានទឹក | ភាគរយនៃទិន្នន័យផលប៉ះពាល់គ្រោះមហន្តរាយដែលប្រមូលបានតាមរយៈ PRISM ត្រូវបានផ្ទេរ និងដាក់ចូលទៅក្នុង CamDi;<br>ចំនួនផលិតផលឬដំណោះស្រាយដែលទទួលបានអត្ថប្រយោជន៍ពីអន្តរប្រតិបត្តិការប្រសើរជាងមុន រវាង PRISM, EWS1294, មូលដ្ឋានទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រ និងថ្នាលចុះបញ្ជីគាំពារសង្គម;<br>ចំនួនផលិតផលឬដំណោះស្រាយដែលទទួលបានអត្ថប្រយោជន៍ពីការចែករំលែកទិន្នន័យប្រសើរជាងមុន រវាង DRR និងវេទិកាព័ត៌មានទាក់ទងនឹងទឹក | ១.២.១.១ អនុវត្តន៍ការគូសផែនទីស្តីពីប្រភពទិន្នន័យគ្រប់ជ្រុងជ្រោយ រួមទាំងទិន្នន័យ ភាពងាយរងគ្រោះសង្គម និងការបែងចែកយេនឌ័រ ដើម្បីណែនាំដល់ការវិនិយោគក្នុងការធ្វើឱ្យប្រសើរឡើងនូវអន្តរប្រតិបត្តិការទិន្នន័យនៅគ្រប់វិស័យដែលពាក់ព័ន្ធនឹងប្រព័ន្ធប្រកាសឱ្យដឹងមុន | NCDM | MoWRAM<br>MRC<br>CNMC<br>GS-NSPC<br>UNDRR<br>WMO<br>UNDP<br>WFP<br>IOM<br>MPTC<br>MOP | x | x | | | ៦៥០ ០០០ | មិនទាន់មានប្រភពថវិកា |
| | | | ១.២.១.២ រៀបចំដំណោះស្រាយផ្នែកព័ត៌មានវិទ្យា និងប្រតិបត្តិការសមស្របមួយ ដើម្បីឱ្យមានការផ្ទេរទិន្នន័យផលប៉ះពាល់គ្រោះមហន្តរាយកម្រិតមូលដ្ឋានរបស់ គ.ជ.គ.ម. ដែលប្រមូលបានតាមរយៈ PRISM ទៅក្នុងមូលដ្ឋានទិន្នន័យការបាត់បង់ និងការខូចខាតនៅថ្នាក់កណ្ដាល (CamDi) (ភ្ជាប់ទៅលទ្ធផលទី ១.១.១)។ | | | | | | | ៧៥០ ០០០ | |

| សសរស្តម្ភទី២ : ការកំណត់ ការត្រួតពិនិត្យ ការវិភាគ និងការព្យាករអំពីគ្រោះថ្នាក់ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង : ពង្រឹងសមត្ថភាពក្នុងការកំណត់ សង្កេត ត្រួតពិនិត្យ វិភាគ និងការព្យាករចំពោះគ្រោះថ្នាក់។ ការពង្រឹងសមត្ថភាពសំខាន់ៗទាំងនេះ ធ្វើឱ្យការព្យាករអាកាសធាតុមានសុក្រឹតភាព និងទាន់ពេល និងការផ្សព្វផ្សាយព័ត៌មានអំពីការប្រកាសឱ្យដឹងមុនដល់សាធារណជន បានប្រសើរឡើង។ | | | | | | | | | | | |
| គោលនយោបាយនិងអាទិភាពរបស់រដ្ឋាភិបាលពាក់ព័ន្ធ : ផែនការសកម្មភាពឆ្នាំ២០២៤ របស់ក្រសួងធនធានទឹកនិងឧតុនិយម | | | | | | | | | | | |
| គម្លាត | លទ្ធផលរំពឹងទុក | សូចនាករណ៍លទ្ធផល | សកម្មភាព | អ្នកទទួលខុសត្រូវ | | ពេលវេលាអនុវត្តន៍ (ឆ្នាំ) | | | | ថវិកា (ដុល្លារ) | ប្រភពថវិកា |
| | | | | ដឹកនាំ | គាំទ្រ | ទី១ | ទី២ | ទី៣ | ទី៤ | | |
| លទ្ធផលកម្រិតមធ្យម ២.១ : ការបង្កើនលទ្ធភាពទទួលបានទិន្នន័យសង្កេតមានគុណភាព ដើម្បីវាយតម្លៃនិងតាមដានគ្រោះថ្នាក់ដែលជាអាទិភាព | | | | | | | | | | | |
| **២.១.១ ស្ថានីយមួយចំនួនដែលគ្រប់គ្រងដោយនាយកដ្ឋានឧតុនិយម បច្ចុប្បន្នមិនដំណើរការ និងមិនមានភាពស្វ័យប្រវត្តិគ្រប់គ្រាន់ ក៏ដូចជាកង្វះការគ្របដណ្តប់ពេញលេញទូទាំងប្រទេស** | ២.១.១ ស្ថានីយធាតុអាកាសស្វ័យប្រវត្តិ (AWS) ច្រើនជាង ៨០% មានដំណើរការពេញមុខងារ និងពង្រីកការគ្របដណ្តប់តាមរយៈការដំឡើងស្ថានីយថ្មី | ស្ថានីយច្រើនជាង៨០% មានដំណើរការពេញមុខងារ និងការថែទាំបានល្អគ្រប់ពេល;<br>ទិន្នន័យសំខាន់ៗត្រូវបានចែករំលែក (បំពេញលក្ខខណ្ឌតម្រូវរបស់ GBON);<br>ចំនួនស្ថានីយធាតុអាកាសស្វ័យប្រវត្តិដែលបានដំឡើង | ២.១.១.១ ទិញគ្រឿងបន្លាស់ និងឧបករណ៍គ្រឿងបន្លាស់ត្រៀមបន្ថែម ដើម្បីដំណើរការស្ថានីយ និងរក្សាឱ្យដំណើរការបានពេញលេញ (រៀបចំផែនការបណ្តាញជលសាស្ត្រ-ឧតុនិយមសម្រាប់ប្រទេស ដោយបញ្ជាក់ពីចំនួនស្ថានីយអប្បបរមាដល់ចំនួនល្អបំផុត និងទីតាំងរបស់វា ផែនការពង្រីក/កែលម្អ ដំណើរការនិងការថែទាំ, និរន្តរភាពហិរញ្ញវត្ថុ ក៏ដូចជាតម្រូវការពីវិស័យអ្នកប្រើប្រាស់ ម្ចាស់ជំនួយ និងដៃគូអនុវត្តន៍) | MoWRAM | WMO | x | x | x | x | ៩៥០ ០០០ | SOFF (GBON) & ADB |
| | | | ២.១.១.២ កំណត់ប្រភពនៃមូលដ្ឋានឧបករណ៍ និងផ្តល់ការកសាងសមត្ថភាពសម្រាប់ការថែទាំ និងផ្ទៀងផ្ទាត់លើឧបករណ៍ | | | | | | | ២៥០ ០០០ | |
| | | | ២.១.១.៣ ដំឡើងស្ថានីយធាតុអាកាសស្វ័យប្រវត្តិថ្មី | | | | | | | ៨០០ ០០០ | |
| លទ្ធផលទី៤ : ការត្រួតពិនិត្យ និងវាយតម្លៃ | ១.៤. ទិន្នន័យផលប៉ះពាល់គ្រោះមហន្តរាយ / ការបាត់បង់ និងការខូចខាត ត្រូវបានតាមដាន និងកត់ត្រាជាប្រព័ន្ធ ស្របតាមគោលដៅ និងសូចនាកររបស់ សេនដាយ និង SDG | ១.៤.ក. ប្រព័ន្ធតាមដាន និងកត់ត្រាអំពីគ្រោះថ្នាក់ និងការបាត់បង់និងការខូចខាតដោយគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង ជាមួយនឹងទិន្នន័យបែងចែកតាមភេទ អាយុ ពិការភាព វិស័យ និងភូមិសាស្ត្រ | មាន | ទិន្នន័យការបាត់បង់ និងការខូចខាតអតិតកាលដែលមានចាប់តាំងពីឆ្នាំ១៩៩៦ នៅក្នុងប្រព័ន្ធ CamDi ។ ទិន្នន័យប្រមូលផ្តុំជុំវិញការស្លាប់ ប្រជាជនដែលរងផលប៉ះពាល់ ការជម្លៀសមនុស្ស ការខូចខាតដំណាំ ( ហិកតា ) ការខូចខាតផ្លូវ។ ភេទ អាយុ ទិន្នន័យពិការភាពជាញឹកញាប់ មិនអាចរកបាន។ ការខាតបង់ក្នុងលក្ខខណ្ឌសេដ្ឋកិច្ចមិនត្រូវបានកត់ត្រាជាប្រព័ន្ធ។ អង្គភាពរដ្ឋបាលថ្មីដែលទើបបង្កើតថ្មីៗនេះចាំបាច់ត្រូវរួមបញ្ចូលទៅក្នុង CamDi ។<br>http://camdi.ncdm.gov.kh/DesInventar/profiletab.jsp?countrycode=kh2&continue=y |
| | | ១.៤.ខ. ទិន្នន័យផលប៉ះពាល់គ្រោះមហន្តរាយអតិតកាលសម្រាប់គ្រោះថ្នាក់អាទិភាពទាំងអស់តាមវិស័យ ( ឧទាហរណ៍ វិសាលភាពភូមិសាស្ត្រ ទំហំ អាំងតង់ស៊ីតេ ប្រេកង់។ល។ ) | មានដោយផ្នែក | ប្រព័ន្ធ CamDi បច្ចុប្បន្ន អាចទាញយកទិន្នន័យអំពីភាពញឹកញាប់នៃព្រឹត្តិការណ៍គ្រោះថ្នាក់ ជាពិសេសនៅក្នុងខេត្ត ស្រុក និងឃុំ ( ក្នុងកម្រិតខ្លះ ) តាមពេលវេលា។ ទោះជាយ៉ាងណា ទិន្នន័យផលប៉ះពាល់តាមវិស័យ មិនត្រូវបានកត់ត្រា និងមិនអាចចេញបានជាប្រព័ន្ធនោះទេ។ |
| | | ១.៤.គ. ព្រឹត្តិការណ៍គ្រោះថ្នាក់អាទិភាពទាំងអស់ត្រូវបានកត់ត្រា និងភ្ជាប់ទៅនឹងរបាយការណ៍ស្តីពីការបាត់បង់ និងការខូចខាត | មាន | ការបាត់បង់ និងការខូចខាតទាក់ទងនឹងការរងគ្រោះរបស់មនុស្ស ផ្ទៃដីដំណាំ ការខូចខាតផ្លូវថ្នល់ អាចរកបាន និងកត់ត្រា តាមរយៈការប្រមូលទិន្នន័យក្រោយផលប៉ះពាល់ នៅក្នុង PRISM ប៉ុន្តែមិនមែនជាតម្លៃសេដ្ឋកិច្ច ( ដោយផ្ទាល់ ឬដោយប្រយោល )។ បន្ទាប់មក ទិន្នន័យត្រូវបានប្រមូលផ្តុំនៅកម្រិតខេត្ត ហើយបញ្ចូលទៅក្នុង CamDi ។ |
| ពហុ | **២. តើភាពប្រឈម ភាពងាយរងគ្រោះ សមត្ថភាព និងហានិភ័យ ត្រូវបានវាយតម្លៃដែរឬទេ ?** | | | |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.១. ការវាយតម្លៃ និងកំណត់បរិមាណនៃការប៉ះពាល់ដល់មនុស្ស សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលធ្វើឡើង និងធ្វើផែនទីសម្រាប់គ្រោះថ្នាក់ពាក់ព័ន្ធទាំងអស់ ក៏ដូចជាហានិភ័យណាមួយ | ២.១.ក. ជំរឿន / ទិន្នន័យស្ទង់មតិលើមនុស្សដែលរងការប៉ះពាល់ : អាយុតិចជាង ៥ឆ្នាំ, ល្បាយលម្អិត, ជាក្រុម | មាន | បាទ, ក្រោម NCDS របស់ក្រសួងបរិស្ថាន។ មានសន្ទស្សន៍ភាពងាយរងគ្រោះដែលកំណត់ឃុំងាយរងគ្រោះចំពោះគ្រោះថ្នាក់អាកាសធាតុ ( ទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ) ដែលជាផ្នែកមួយនៃក្របខ័ណ្ឌជាតិត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ, SDG13, NSDP ២០១៩-២០២៣។ ទិន្នន័យបឋមមកពីមូលដ្ឋានទិន្នន័យឃុំរបស់កម្ពុជា។ ទិន្នន័យដើមដែលបានពីទិន្នន័យឃុំសង្កាត់ មិនត្រូវបានធ្វើសមកាលកម្មជាមួយប្រព័ន្ធរបស់ NCDM ហើយមិនត្រូវបានប្រើសម្រាប់ការធ្វើ |

| | | | | |
|---|---|---|---|---|
| | នៅកម្រិតមូលដ្ឋានទាំងនៅតំបន់ជនបទ ទីប្រជុំជន និងឆ្នេរសមុទ្រ | | | ផែនការ NCP ទេ។ https://ncsd.moe.gov.kh/dcc/data-portal/vulnerability-climate-hazards |
| | | ២.១.ខ. សារពើភណ្ឌ និងមូលដ្ឋានទិន្នន័យនៃហេដ្ឋារចនាសម្ព័ន្ធដែលបានប៉ះពាល់ : អាយុតិចជាង ១០ឆ្នាំ; ល្បាយលម្អិត, ជាក្រុម | មិនមាន | មិនមានសារពើភណ្ឌជាក់លាក់ ឬមូលដ្ឋានទិន្នន័យអំពីភាពប្រឈមនៃហេដ្ឋារចនាសម្ព័ន្ធ ដែលអាចរកបាននោះឡើយ។ |
| | | ២.១.គ. សារពើភណ្ឌ និងមូលដ្ឋានទិន្នន័យប្រឈមនៃដីកសិកម្មដែលប៉ះពាល់ ទ្រព្យសម្បត្តិជាដើម : អាយុតិចជាង ១០ឆ្នាំ; ល្បាយលម្អិត, ជាក្រុម | មិនមាន | គ្មានមូលដ្ឋានទិន្នន័យអំពីភាពប្រឈមលើកសិកម្មទេ។ ការស្ទង់មតិកសិកម្មកម្ពុជាឆ្នាំ ២០២១ បានប្រមូលព័ត៌មានស្តីពីការដាំដុះដំណាំ, ការចិញ្ចឹមសត្វ និងបសុបក្សី, វារីវប្បកម្ម និងការនេសាទ, ផលប៉ះពាល់នៃគ្រោះអាសន្នក្រៅកសិកម្ម, ការងារ, សេដ្ឋកិច្ច, និងផ្សេងៗទៀត។ https://microdata.nis.gov.kh/index.php/catalog/38/related-materials |
| | | ២.១.ឃ. សារពើភណ្ឌ និងមូលដ្ឋានទិន្នន័យប្រឈមនៃសេវាកម្មដែលប៉ះពាល់ : អាយុតិចជាង ៥ឆ្នាំ; ល្បាយលម្អិត, ជាក្រុម | មិនមាន | |
| | | ២.១.ង. សារពើភណ្ឌ និងមូលដ្ឋានទិន្នន័យប្រឈមនៃសេវាអេកូឡូស៊ី : អាយុតិចជាង ១០ ឆ្នាំ; ល្បាយលម្អិត, ជាក្រុម | មិនមាន | ប្រព័ន្ធទិន្នន័យ CAMStat មិនមានសូចនាករលើប្រព័ន្ធអេកូឡូស៊ី ឬសេវាកម្មប្រព័ន្ធអេកូឡូស៊ី ការប៉ះពាល់ គ្រោះថ្នាក់ ឬការប្រែប្រួលអាកាសធាតុទេ។ |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.២. ទិន្នន័យស្តីពីភាពប្រឈម, ភាពងាយរងគ្រោះ, ផលប៉ះពាល់ (ការបាត់បង់ និងការខូចខាត), ផ្ទៃដីប្រមូលផល, និងផលិតកម្ម ត្រូវបានប្រមូល ហើយហានិភ័យត្រូវបានវាយតម្លៃនៅក្នុងវិស័យកសិកម្ម-អាហារ (ដំណាំ សត្វ ព្រៃឈើ នេសាទ វារីវប្បកម្ម) សម្រាប់គ្រោះថ្នាក់ខ្លាំងជាងគេទាំង៥ (គ្រោះថ្នាក់ដែលបានឆ្លើយតប ៩០% នៃ ការបាត់បង់ និងខូចខាត(L&D) កន្លងមកនៅក្នុងវិស័យ) | ២.២.ក. មូលដ្ឋានទិន្នន័យស្តីពីផលប៉ះពាល់គ្រោះមហន្តរាយ និងការវាយតម្លៃហានិភ័យសម្រាប់វិស័យកសិកម្ម-អាហារ; ទិន្នន័យត្រូវបានបែងចែក (តាមដំណាំ សត្វ។ល។) សម្រាប់រយៈពេល ៥ឆ្នាំមុន និងធ្វើបច្ចុប្បន្នភាពជាទៀងរាល់ឆ្នាំ; ការវាយតម្លៃហានិភ័យបានធ្វើបច្ចុប្បន្នភាពទៀងរាល់ ៥ឆ្នាំម្តង។ | មានដោយផ្នែក | CamDi ក៏មានទិន្នន័យប្រចាំឆ្នាំ (តាមកម្រិតរដ្ឋបាល ឃុំ ស្រុក ខេត្ត និងជាតិ) អំពីផលប៉ះពាល់ទឹកជំនន់លើដំណាំដែលខូចខាត និងសត្វពាហនៈដែលបាត់បង់ ចាប់តាំងពីឆ្នាំ១៩៩៦។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមដានកត់ត្រាពីផលប៉ះពាល់គ្រោះមហន្តរាយលើទ្រព្យធនកសិកម្ម។ |
| លទ្ធផល១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៣. ផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងហានិភ័យបន្ទាប់បន្សំដែលទាក់ទងនឹងផលប៉ះពាល់ទាំងនេះ ត្រូវបានវាយតម្លៃ ហើយដំណោះស្រាយគ្រប់គ្រងហានិភ័យ ត្រូវបានយកចិត្តទុកដាក់ដើម្បីបង្កើនភាពធន់។ | ២.៣.ក. វិធីសាស្ត្រវាយតម្លៃផលប៉ះពាល់ រួមទាំងការវាយតម្លៃភាពងាយរងគ្រោះ និងសមត្ថភាពដោះស្រាយ | មិនមាន | |
| | | ២.៣.ខ. ការវិភាគផលប៉ះពាល់ដែលអាចកើតមាន និងការធ្វើតេស្តកម្រិតស្ត្រេសនៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ | មិនមាន | |
| | | ២.៣.គ. ការវិភាគហានិភ័យជាលំដាប់ចំពោះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងផលប៉ះពាល់បន្ទាប់បន្សំចំពោះប្រព័ន្ធសេដ្ឋកិច្ច-សង្គម | មិនមាន | |

| | | | | |
|---|---|---|---|---|
| លទ្ធផល១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៤. កត្តានៃងាយរងគ្រោះ ដូចជាយេនឌ័រ ពិការភាព ការទទួល-ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ពិពិធភាពសេដ្ឋកិច្ច វិសមភាពសង្គម និងភាពរួសនៃបរិស្ថាន ត្រូវបានយកចិត្តទុកដាក់ | ២.៤.ក ទិន្នន័យជំរឿន និងការស្ទង់មតិស្តីពីយេនឌ័រ ពិការភាព ស្ថានភាពសេដ្ឋកិច្ច ជីវភាពរស់នៅ លទ្ធភាពទទួលបានសេវាកម្មជាដើម៖ តិចជាង ៥ឆ្នាំ, ច្បាស់លាស់, និងបែងចែក | មាន | ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ឆ្នាំ២០២១ ដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។ ទិន្នន័យស្តីពីលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម របស់គ្រួសារទូទាំងប្រទេស។ ការធ្វើម្តងទៀតសម្រាប់ឆ្នាំ ២០២៤/២៥ ។ មូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ (IDPoor) ដោយនាយកដ្ឋានកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។ ស្ថានភាពចាប់ពីមានកម្រិត រហូតដល់ការមិនមានអនុវត្តព័ត៌មាននេះនៅទូទាំងប្រព័ន្ធ NCP/DRM។ |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៥. ភាពងាយរងគ្រោះនៃវិស័យសេដ្ឋកិច្ចសំខាន់ៗនៅថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ត្រូវបានវាយតម្លៃ | ២.៥.ក ទិន្នន័យស្ទង់មតិ, កំណត់ត្រានៃព្រឹត្តិការណ៍កន្លងមក, មូលដ្ឋានទិន្នន័យនៃការបាត់បង់ និងការខូចខាត, PDNA : ក្រោម ៥ ឆ្នាំ, ការរកឃើញដែលបានចងក្រង និងផ្តល់សុពលភាពដោយភាគីពាក់ព័ន្ធសំខាន់ៗ | មានដោយផ្នែក | ទិន្នន័យការបាត់បង់ និងការខូចខាត (ភាគច្រើនដោយទឹកជំនន់) ចាប់តាំងពីឆ្នាំ១៩៩៦ មាននៅក្នុងប្រព័ន្ធ CamDi ។<br><br>ភាពងាយរងគ្រោះនៃអាកាសធាតុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ទំនាក់ទំនងជាតិលើកទីបី (TNC) របស់ក្រសួងបរិស្ថានដែលបានដាក់ជូនទៅ UNFCCC បោះពុម្ពផ្សាយក្នុងខែកញ្ញា ឆ្នាំ ២០២២។ វិស័យងាយរងគ្រោះសំខាន់ៗដែលបានពិភាក្សារួមមាន កសិកម្ម ធនធានទឹក សុខភាព និងតំបន់ឆ្នេរសមុទ្រ បូករួមទាំងពហុវិស័យនៃយេនឌ័រ (សូមមើល ១.៣.ក សម្រាប់តំណភ្ជាប់)។ |
| លទ្ធផលទី៦ : ចំណេះដឹងក្នុងមូលដ្ឋាន និងជនជាតិដើមភាគតិច (ILK) សម្រាប់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៦. ចំណេះដឹងក្នុងមូលដ្ឋាន និងជនជាតិដើមភាគតិច (ILK) ត្រូវបានដាក់បញ្ចូលទៅក្នុងការវាយតម្លៃហានិភ័យ | ២.៦.ក. ប្រព័ន្ធការងារស្ថិតិមានជាស្រេច ដើម្បីប្រមូល គ្រប់គ្រង និងវិភាគព័ត៌មានហានិភ័យ និងរួមបញ្ចូលទិន្នន័យកម្រិតមូលដ្ឋាន និងសហគមន៍ : ធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ឆ្នាំម្តង។ | មិនមាន | គណៈកម្មាធិការជាតិអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCSDD) ដំណើរការមូលដ្ឋានទិន្នន័យឃុំសង្កាត់ (CDB)។ ទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ CDB ប្រមូលព័ត៌មានប្រជាសាស្ត្រ សង្គម និងសេដ្ឋកិច្ចមូលដ្ឋានដែលប្រមូលផ្តុំតាមថ្នាក់ភូមិ ឃុំ និងស្រុក។ ការប្រមូលព័ត៌មានមូលដ្ឋានអំពីចំនួនគ្រួសារជនជាតិភាគតិច/ជនជាតិដើមភាគតិចដែលរស់នៅក្នុងឃុំផ្សេងៗគ្នា។ មិនមានប្រព័ន្ធជាតិណាមួយដែលនឹងធ្វើការជាប្រព័ន្ធជាមួយទិន្នន័យនេះសម្រាប់ការវាយតម្លៃហានិភ័យ ឬគោលបំណងពាក់ព័ន្ធនោះទេ។ |
| | | ២.៦.ខ. ការចងក្រងចំណេះដឹងអំពីជនជាតិដើមភាគតិច/មូលដ្ឋាន ដែលប្រើដោយសហគមន៍មូលដ្ឋានដើម្បីកំណត់ហានិភ័យ | មិនមាន | គ្មានចំណេះដឹងអំពីជនជាតិដើមភាគតិច/មូលដ្ឋាន ដែលបានចងក្រងជាប្រព័ន្ធសម្រាប់គោលបំណងវាយតម្លៃហានិភ័យទេ។ សូមមើលខាងលើ។ |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៧. សកម្មភាពដែលបង្កើនហានិភ័យ (ឧទាហរណ៍ នគរូបនីយកម្ម និងការប្រើប្រាស់ដី) ដែលបានកំណត់ និងវាយតម្លៃ (សមត្ថភាពកម្រិតខ្ពស់ក៏ត្រូវរាប់បញ្ចូល បើពាក់ព័ន្ធ) | ២.៧.ក របាយការណ៍វាយតម្លៃកត្តាហានិភ័យពាក់ព័ន្ធនៅថ្នាក់ជាតិ : ឧទាហរណ៍ ការបង្កើតទីក្រុង ផលិតផលស្បៀងអាហារ ហេដ្ឋារចនាសម្ព័ន្ធ ប្រជាសាស្ត្រ ការប្រើប្រាស់ដី | មិនមាន | |
| លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន | ២.៨. លទ្ធផលវាយតម្លៃហានិភ័យរួមបញ្ចូលទៅក្នុងផែនការគ្រប់គ្រងហានិភ័យនៅមូលដ្ឋាន ហើយសារប្រកាសអាសន្នក្នុងភាសាច្បាស់លាស់ និងងាយយល់ ដោយយកចិត្តទុកដាក់លើរបៀបដែលមនុស្សផ្សេងៗគ្នាទទួលបានព័ត៌មាន | ២.៨.ក. ផែនការ DRR/M ថ្នាក់ជាតិ និងមូលដ្ឋានជាមួយនឹងផ្នែកបរិមាណស្តីពីភាពងាយរងគ្រោះ ការប៉ះពាល់ និងប្រវត្តិនៃការបាត់បង់ | មានដោយផ្នែក | NAP-DRR ២០១៨-២០២៣ មានការពិពណ៌នាបរិមាណដោយប្រមូលព័ត៌មានពីការសិក្សាខាងក្រៅ។ នៅថ្នាក់ខេត្ត ចំនួនក្រុមងាយរងគ្រោះបានមកពីទិន្នន័យគ្រួសារក្រីក្រ (IDPoor)។ |
| | | ២.៨.ខ. សារនៃប្រព័ន្ធប្រកាសឱ្យដឹងមុន ត្រូវបានពិនិត្យលើទិន្នន័យទាំងបីផ្នែកនៃ គ្រោះថ្នាក់ ភាពងាយរងគ្រោះ និងភាពប្រឈម | មានដោយផ្នែក | សារថតជាសំឡេងអំពីប្រកាសឱ្យដឹងមុន ត្រូវបានផ្សព្វផ្សាយដល់មនុស្សមួយចំនួន (អ្នកដែលបានចុះឈ្មោះ) នៃប្រព័ន្ធ EWS1294 តាមរយៈការហៅទូរសព្ទ តេឡេក្រាម វិទ្យុ ឬឧបករណ៍បំពងសំឡេងនៅទីប្រជុំជន។ EWS1294 ត្រូវបានគ្រប់គ្រងដោយ NCDM និងប្រើឧបករណ៍សម្រាប់វាស់កម្ពស់ទឹកទន្លេដែលមាននៅតាមដងទន្លេ។ ព័ត៌មានព្យាករណ៍ពី MoWRAM ត្រូវបានពិចារណា នៅពេលធ្វើការសម្រេចចិត្តអំពីការផ្សព្វផ្សាយជូនដំណឹង ប៉ុន្តែមិនមានពិធីសារស្តង់ដាក្នុងការប្រើប្រាស់នៅឡើយទេ។<br><br>ជាទូទៅ ផលិតផលព្យាករណ៍ទឹកជំនន់ដែលមាន នៅពុំទាន់អាចជឿជាក់បាន និងមិនមានការប្រឹក្សាជាក់លាក់តាមវិស័យដែលរងផលប៉ះពាល់ឡើយ។ |

| | | | | |
|---|---|---|---|---|
| | | | | ជនជាតិភាគតិចដែលមិននិយាយភាសាខ្មែរមួយចំនួន (ឧទាហរណ៍ សហគមន៍វៀតណាម) អាចមានកម្រិតក្នុងការទទួលបានការជូនដំណឹងប្រកាសអាសន្នជាមុន។ |
| លទ្ធផលទី៦ : ចំណេះដឹងក្នុងមូលដ្ឋាន និងជនជាតិដើមភាគតិច (ILK) សម្រាប់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ២.៩. បទដ្ឋានគតិយុត្ត និងផ្នត់គំនិតវប្បធម៌ដែលបានវាយតម្លៃ ដើម្បីកំណត់គម្លាតដែលអាចនាំឱ្យមានបង្កើនភាពងាយរងគ្រោះ | ២.៩.ក. ការសិក្សាពីការយល់ឃើញស្តីពីហានិភ័យ និងប្រព័ន្ធប្រកាសឱ្យដឹងមុន | មាន | ការសិក្សាលើកទី៣ ស្តីពីការស្វែងយល់ពីទស្សនៈជាសាធារណៈ ចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា : ចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP3), ឆ្នាំ២០២១ ។ ការធ្វើម្តងទៀតចុងក្រោយដែលត្រូវបានអនុញ្ញាតដោយក្រសួងបរិស្ថាន មានគោលបំណងទាញយកកស្តុតាងនៃបទពិសោធរបស់ប្រជាជនកម្ពុជាចំពោះការប្រែប្រួលអាកាសធាតុ និងបរិស្ថានរបស់ពួកគេ ដើម្បីជាទិន្នន័យសម្រាប់ការសម្រេចចិត្តលើយុទ្ធសាស្ត្រទាក់ទំនងនាពេលអនាគត និងកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។ មិនមានភាពច្បាស់លាស់ថាតើព័ត៌មាននេះត្រូវបានប្រើដោយ NCDM ដើម្បីជាធាតុចូលសម្រាប់ការអនុវត្តNCP ដែរឬទេ។ ការសិក្សា KAP4 នឹងត្រូវបានបោះពុម្ពនៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤។ https://ncsd.moe.gov.kh/resources/document/KAP3_EN |
| **លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ** | **៣. តើតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធត្រូវបានកំណត់ដែរឬទេ ?** | | | |
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៣.១. ស្ថាប័នរបស់រដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធក្នុងការវាយតម្លៃហានិភ័យ ត្រូវបានកំណត់ ហើយតួនាទីត្រូវបានកំណត់តាមរយៈយន្តការផ្លូវការ/ច្បាប់ | ៣.១.ក. ស្ថាប័នត្រូវបានកំណត់អាណត្តិ តួនាទីទំនួលខុសត្រូវ និងមន្ត្រីបង្គោលបច្ចេកទេសសម្រាប់ការប្រកាសឱ្យដឹងមុន | មាន | ច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៥។ NCDM ជាស្ថាប័នសម្របសម្រួល ហើយក្រសួងពាក់ព័ន្ធនីមួយៗផ្តល់មន្ត្រីបង្គោលសម្រាប់ DRR (មិនមែនសម្រាប់តែ EWS នោះទេ) ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែង នៅមានកម្រិត។ |
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៣.២. ច្បាប់ ឬគោលនយោបាយរបស់រដ្ឋាភិបាលដែលតម្រូវឱ្យរៀបចំការវាយតម្លៃគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាពសម្រាប់គ្រប់វិស័យត្រូវបានរៀបចំ | ៣.២.ក. ច្បាប់ផ្លូវការ ឯកសារគោលនយោបាយ និងអាណត្តិ ត្រូវបានបង្កើតឡើង និងអនុម័ត | មាន | ច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៥។<br>ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០២៤-២០២៨។<br>ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ២០២៤-២០៣៣។<br>ការប្តេជ្ញាចិត្ត NDC; តួនាទីរបស់ MoWRAM នៅក្នុង NDC គឺដើម្បី "បង្កើតប្រព័ន្ធថ្នាក់ជាតិស្តីពីប្រកាសអាសន្ននៃអាកាសធាតុ និងអាហារ រួមទាំងមជ្ឈមណ្ឌលសេវាកម្ម និងផែនការឆ្លើយតបបន្ទាន់ចំពោះទឹកជំនន់"។ |
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៣.៣. ការទទួលខុសត្រូវក្នុងការសម្របសម្រួលលើការកំណត់អត្តសញ្ញាណគ្រោះថ្នាក់ និងព័ត៌មានហានិភ័យដែលបានចាត់ចែងឱ្យអង្គការជាតិមួយ ដោយរួមដាក់បញ្ចូលវិធីសាស្ត្រជាច្រើន និងការត្រួតពិនិត្យទំនាក់ទំនង និងផលប៉ះពាល់ជាលំដាប់ | ៣.៣.ក. ស្ថាប័នបង្គោលថ្នាក់ជាតិដែលមានកាតព្វកិច្ចផ្លូវការលើព័ត៌មានហានិភ័យ | មាន | NCDM, ដូចមានចែងក្នុងច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៥។ |

| | | | | |
|---|---|---|---|---|
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៣.៤. ដំណើរការស្តង់ដាដែលបានបង្កើតឡើងសម្រាប់អ្នកជំនាញវិទ្យាសាស្ត្រ និងបច្ចេកទេស ដើម្បីវាយតម្លៃ និងពិនិត្យមើលភាពត្រឹមត្រូវនៃទិន្នន័យ និងព័ត៌មានហានិភ័យ | ៣.៤.ក. ក្រុមអ្នកជំនាញបានបណ្តុះបណ្តាលស្តីពីការប្រមូល ផលិតផល ការផ្ទៀងផ្ទាត់ ការប្រើប្រាស់ និងការផ្សព្វផ្សាយព័ត៌មានហានិភ័យ | មានដោយផ្នែក | សមត្ថភាពក្នុងការប្រមូលព័ត៌មានក្រោយផលប៉ះពាល់ដោយប្រើឧបករណ៍ PRISM, ប្រព័ន្ធ CamDi សម្រាប់ការបាត់បង់ និងការខូចខាត។ មានជំនាញគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យហានិភ័យទឹកជំនន់ និងប្រកាសអាសន្នតាមរយៈ EWS1294 នៅកម្រិត NCDM/PCDM ។ គ្មានការអនុវត្តការវាយតម្លៃហានិភ័យជាប្រព័ន្ធ ដែលជាផ្នែកមួយនៃសកម្មភាពត្រៀមបម្រុង មួយផ្នែកដោយសារតែខ្វះថវិកា និងធនធានមនុស្ស ។ |
| លទ្ធផលទី៥៖ ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៣.៥. ដំណើរការដែលបានបង្កើតឡើង ដើម្បីឱ្យសហគមន៍នៅជនបទ និងទីប្រជុំជនចូលរួមយ៉ាងសកម្មក្នុងការវាយតម្លៃគ្រោះថ្នាក់ និងហានិភ័យនៅមូលដ្ឋាន ដោយគិតគូរពីតម្រូវការរបស់មនុស្សទាំងអស់ (ស្ត្រី កុមារ មនុស្សចាស់ ជនមានពិការភាព។ល។) | (ដូចចំណុច ២.៤.ក ខាងលើ) | មានដោយផ្នែក | ភាគីពាក់ព័ន្ធថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានបានចូលរួមក្នុងការធ្វើផែនការត្រៀមបម្រុងនៅតាមបណ្តាលខេត្តអាទិភាព។ មិនមានការវាយតម្លៃហានិភ័យគ្រោះថ្នាក់ជាលក្ខណៈប្រព័ន្ធត្រូវបានអនុវត្តទេ។ |
| **ពហុ** | **៤. តើព័ត៌មានហានិភ័យត្រូវបានបញ្ចូលគ្នាទេ ?** | | | |
| លទ្ធផលទី២ : បើកឱ្យមានការចូលប្រើព័ត៌មានអំពីពីហានិភ័យដោយសេរី | ៤.១. មជ្ឈមណ្ឌលឯកសារស្តង់ដាថ្នាក់កណ្តាល (រួមទាំង, ប៉ុន្តែមិនកំណត់ចំពោះ, ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ) ដែលបានបង្កើតឡើងដើម្បីរក្សាទុកព័ត៌មានព្រឹត្តិការណ៍/គ្រោះមហន្តរាយ និងហានិភ័យទាំងអស់ | ៤.១.ក. មូលដ្ឋានទិន្នន័យព័ត៌មានហានិភ័យ, ម៉ាស៊ីនមេ (server), និងវេទិកាចំណេះដឹង៖ ចំពោះគ្រោះថ្នាក់អទីភាពទាំង៥ បានធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ និងម៉ាស៊ីនមេដែលត្រូវបានពិនិត្យសេវាប្រចាំឆ្នាំ | មានដោយផ្នែក | **NCDM** - CamDi រក្សាទុកព័ត៌មានស្តីពីការបាត់បង់និងការខូចខាត; PRISM មានទិន្នន័យប្រវត្តិថ្មីៗអំពីព្រឹត្តិការណ៍គ្រោះថ្នាក់ទឹកជំនន់ និងផលប៉ះពាល់របស់វា។ មិនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យចំពោះពហុគ្រោះថ្នាក់នៅក្នុងប្រទេសទេ។<br><br>**MoE** - NCSD Portal : មានសន្ទស្សន៍ភាពងាយរងគ្រោះ (VI) សម្រាប់គ្រោះថ្នាក់ចំនួន ៣ប្រភេទ (ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត) ចាប់ពីឆ្នាំ២០១៤ ដល់ ២០២២ |
| លទ្ធផលទី៤ : ការត្រួតពិនិត្យ និងវាយតម្លៃ | ៤.២. ស្តង់ដាជាតិ (កន្លែងដែលអាចធ្វើទៅបានតាមស្តង់ដាអន្តរជាតិ) ដែលបានបង្កើតឡើងសម្រាប់ការប្រមូល ចែករំលែក និងវាយតម្លៃព័ត៌មាន និងទិន្នន័យហានិភ័យជាប្រព័ន្ធ ទាក់ទងនឹងគ្រោះថ្នាក់ ភាពប្រឈម ភាពងាយរងគ្រោះ និងសមត្ថភាព (ប្រើប្រាស់ដំណើរការឆ្លើយតបយេនឌ័រនៅពេលដែលអាចធ្វើទៅបាន) | ៤.២.ក. វឌ្ឍនភាពជាតិលើគោលដៅ G បានរាយការណ៍នៅក្នុងការត្រួតពិនិត្យនៃក្របខ័ណ្ឌសេនដាយ សម្រាប់រយៈពេល ៥ឆ្នាំកន្លងទៅ | មានដោយផ្នែក | ប្រទេសកម្ពុជាមិនទាន់បានរាយការណ៍អំពីគោលដៅ G នៅលើការត្រួតពិនិត្យនៃក្របខ័ណ្ឌសេនដាយនៅឡើយទេ។ ដំណើរការនៃការវិភាគគម្លាតរបស់ EW4All នឹងជួយរាយការណ៍អំពីគោលដៅ G ។ ព័ត៌មានលម្អិតបន្ថែមនៅក្នុងរបាយការណ៍ពិនិត្យដោយស្ម័គ្រចិត្តរបស់កម្ពុជាស្តីពីការអនុវត្តក្របខ័ណ្ឌសេនដាយ ត្រូវបានបោះពុម្ពចេញនៅខែតុលា ឆ្នាំ២០២២។<br>តំណភ្ជាប់ : https://sendaiframework-mtr.undrr.org/publication/cambodia-voluntary-national-report-mtr-sf |
| | | ៤.២.ខ. សំណុំស្តង់ដាស្ថិតិជាតិសម្រាប់ព័ត៌មានហានិភ័យ : ការប្រមូល ការគ្រប់គ្រង ការវិភាគ ការប្រើប្រាស់ និងការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានហានិភ័យ បានធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ឆ្នាំម្តង | មានដោយផ្នែក | CamDi គឺជាប្រព័ន្ធនៃការអនុវត្តក្នុងក្របខ័ណ្ឌសេនដាយ គ្រប់គ្រងដោយ NCDM ដែលអាចចាត់ទុកថាជាស្តង់ដាស្ថិតិជាតិសម្រាប់ព័ត៌មានហានិភ័យ។ ទោះជាយ៉ាងណា CamDi បច្ចុប្បន្នផ្តោតលើកំណត់ត្រាទិន្នន័យស្តីពីការបាត់បង់ និងការខូចខាតនៃព្រឹត្តិការណ៍គ្រោះមហន្តរាយនាពេលកន្លងមក។ |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ៤.៣. ទិន្នន័យ និងព័ត៌មានភាពងាយរងគ្រោះតាមស្តង់ដាបែងចែកតាមភេទ អាយុ និងពិការភាព | (ដូចចំណុច ២.៤.ក ខាងលើ) | មាន | កម្ពុជាមានវិធីសាស្ត្រផ្អែកលើភាពក្រីក្រដើម្បីកំណត់ភាពងាយរងគ្រោះតាមរយៈប្រព័ន្ធហៅថា 'IDPoor' ដែលគ្រប់គ្រងដោយក្រសួងផែនការ។ កម្មវិធីជំនួយសង្គមគាំទ្រលើក្រុមនៃគ្រួសារក្រីក្រអាទិភាពក្នុងចំណោមប្រជាជន។ តំណភ្ជាប់ : https://idpoor.gov.kh/en/ |

| | | | | |
|---|---|---|---|---|
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ៤.៤. ដំណើរការដែលបានបង្កើតឡើងដើម្បីរក្សាពិនិត្យឡើងវិញជាប្រចាំ និងធ្វើបច្ចុប្បន្នភាពលើទិន្នន័យហានិភ័យ រួមទាំងព័ត៌មានអំពីភាពងាយរងគ្រោះ និងគ្រោះថ្នាក់ថ្មី ឬដែលកំពុងកើតឡើងជាមួយនឹងតួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធដែលបានកំណត់អត្តសញ្ញាណរួមជាមួយនឹងមូលនិធិសមស្រប | (ដូចចំណុច ២.៤.ក ខាងលើ) | មិនមាន | |
| **លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន** | **៥. តើព័ត៌មានហានិភ័យត្រូវបានបញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងប្រព័ន្ធ ប្រកាសឱ្យដឹងមុន?** | | | |
| លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធ ប្រកាសឱ្យដឹងមុន | ៥.១. ព័ត៌មានស្តីពីវិសាលភាពភូមិសាស្ត្រនៃគ្រោះថ្នាក់ ដែលប្រើដើម្បីកំណត់តំបន់សុវត្ថិភាព និងតំបន់ជម្លៀស | ៥.១.ក. ផ្លូវជម្លៀស ផែនទី និងផែនទីតំបន់សុវត្ថិភាព (រួមទាំងជម្រក) ដែលប្រើព័ត៌មានហានិភ័យ, ភាពងាយរងគ្រោះ និងភាពប្រឈម, ការវាយតម្លៃ, ម៉ូដែល, ការព្យាករ, និងចំណេះដឹងទូទៅ (វិទ្យាសាស្ត្រ និងប្រពៃណី) | មានដោយផ្នែក | ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្ន (CP) របស់ខេត្ត មានបញ្ជីទីតាំងសុវត្ថិភាព (ជាធម្មតាអគារសាធារណៈនៅក្នុងតំបន់ដូចជាសាលារៀន ឬវត្ត)។ គ្មានប្រព័ន្ធកម្រិតជាតិ ដើម្បីតាមដានទីតាំងសុវត្ថិភាពដែលមាននៅទូទាំងប្រទេស។ CPs ក៏មានព័ត៌មានមូលដ្ឋានសម្រាប់ស្ថានភាពគ្រាអាសន្ន រួមទាំងផែនទីផងដែរ។ ប៉ុន្តែ ការវាយតម្លៃជាក់លាក់ ម៉ូដែល ឬការព្យាករមិនមែនជាផ្នែកមួយនៃដំណើរការស្តង់ដានោះទេ។ |
| លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធ ប្រកាសឱ្យដឹងមុន | ៥.២. ព័ត៌មានហានិភ័យលើក្រុមងាយរងគ្រោះ (គ្រោះថ្នាក់ ភាពប្រឈម ភាពងាយរងគ្រោះខុសគ្នា) ដែលប្រើដើម្បីកំណត់ និងឱ្យនិយមន័យនៃផ្លូវជម្លៀស និងទីតាំងជម្រកបណ្តោះអាសន្ន | (ដូចចំណុច ២.៤.ក ខាងលើ) | មានដោយផ្នែក | មិនមានផែនការជាក់លាក់សម្រាប់ក្រុមងាយរងគ្រោះទេ។ ជម្រកបណ្តោះអាសន្នជាធម្មតាត្រូវបានកំណត់ជាមុន (ភាគច្រើនជាវត្ត សាលារៀន) និងប្រើប្រាស់ដោយសមាជិកសហគមន៍ដែលបានជម្លៀសទាំងអស់។ |
| លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន | ៥.៣. ព័ត៌មានហានិភ័យលើប្រភេទផ្សេងៗគ្នានៃទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សេវាកម្ម និងអាជីវកម្ម ត្រូវបានពិនិត្យឡើងវិញដើម្បីបង្ហាញនីតិវិធីក្នុងការកាត់បន្ថយការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិទាំងនោះនៅពេលដែលការប្រកាសអាសន្នត្រូវបានចេញ | (ដូចចំណុច ៥.១.ក ខាងលើ) | មានដោយផ្នែក | ព័ត៌មានអាចរកបានតែជាផ្នែកមួយនៃការវាយតម្លៃតម្រូវការក្រោយផលប៉ះពាល់ ដែលធ្វើឡើងដោយ PCDMs និងការវាយតម្លៃលម្អិតបន្ថែមទៀតអំពីការខូចខាតដោយក្រសួងនៅពេលក្រោយ។ ព័ត៌មានស្តីពីទ្រព្យសម្បត្តិសំខាន់ៗ មិនត្រូវបានរួមបញ្ចូលទៅក្នុងសកម្មភាពត្រៀមបម្រុងទេ។ |
| **លទ្ធផលទី២ : បើកឱ្យមានការចូលប្រើព័ត៌មានអំពីពីហា** | **៦. តើមានការទទួលបានព័ត៌មានអំពីហានិភ័យបានទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែរឬទេ?** | | | |
| លទ្ធផលទី២ : បើកឱ្យមានការចូលប្រើព័ត៌មានអំពីពីហានិភ័យដោយសេរី | ៦.១. តើព័ត៌មានហានិភ័យបច្ចុប្បន្នអាចទទួលបានដោយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ ក្នុងភាពងាយស្រួលដែរឬទេ? | ៦.១.ក. វេទិកាទទួលបានព័ត៌មានដោយសេរីនៅថ្នាក់ជាតិ (គេហទំព័រ ប្រព័ន្ធទិន្នន័យ។ល។) ត្រូវបានប្រើ ដើម្បីរក្សាទុក ការប្រើប្រាស់ ចែករំលែក និងផ្សព្វផ្សាយព័ត៌មានហានិភ័យថ្មីៗ ដោយអនាមិក | មាន | **NCDM** - CamDi, PRISM និង EWS1294 អាចចូលប្រើបានដោយ NCDM និងចែករំលែកជាមួយដៃគូពាក់ព័ន្ធជាតិតាមការស្នើសុំ។ ព័ត៌មានមួយចំនួន នៅលើ PRISM, CamDi និង EWS1294 គឺជាប្រភពព័ត៌មានហានិភ័យដែលអាចមើលបានជាសាធារណៈ ប៉ុន្តែព័ត៌មានខ្លះមិនអាចមើល ឬប្រើបានដោយសាធារណៈទេ។<br>**MoE** - ព័ត៌មានហានិភ័យបច្ចុប្បន្នមាននៅលើវេបសាយរបស់ NCSD : សន្ទស្សន៍ភាពងាយរងគ្រោះ |

| | | | | |
|---|---|---|---|---|
| | | | | (VI) មានសម្រាប់គ្រោះថ្នាក់ចំនួន ៣ប្រភេទ (ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត) ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០២៤ |
| លទ្ធផលទី២ : បើកឱ្យមានការចូលប្រើព័ត៌មានអំពីពីហានិភ័យដោយសេរី | ៦.២. ព័ត៌មានហានិភ័យកម្រិតមូលដ្ឋានថ្មីៗអាចប្រើបានដោយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងសាធារណៈជន បានយ៉ាងងាយស្រួល | ៦.២.ក. វេទិកាទទួលបានព័ត៌មានដោយសេរីនៅថ្នាក់មូលដ្ឋាន (គេហទំព័រ ប្រព័ន្ធទិន្នន័យ។ល។) ត្រូវបានប្រើ ដើម្បីរក្សាទុក ការប្រើប្រាស់ ចែករំលែក និងផ្សព្វផ្សាយព័ត៌មានហានិភ័យថ្មីៗ ដោយអនាមិក | មានដោយផ្នែក | មូលដ្ឋានទិន្នន័យ/គេហទំព័រខាងលើអាចចូលប្រើបានដោយសេរី ប៉ុន្តែមានកម្រិតក្នុងការទទួលយកនៅថ្នាក់មូលដ្ឋាន។ |
| **លទ្ធផលទី៧ : នវានុវត្តន៍សម្រាប់ចំណេះដឹងហានិភ័យ** | **៧. តើការច្នៃប្រឌិតថ្មីត្រូវបានលើកកម្ពស់សម្រាប់ការបង្កើនចំណេះដឹងហានិភ័យ និងការកែលម្អដែរឬទេ?** | | | |
| លទ្ធផលទី៧ : នវានុវត្តន៍សម្រាប់ចំណេះដឹងហានិភ័យ | ៧.១. បច្ចេកវិទ្យាថ្មី ឬបច្ចេកវិទ្យាកម្រិតខ្ពស់ដែលត្រូវបានប្រើសម្រាប់ការប្រមូល ការផលិត ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ព័ត៌មានហានិភ័យ | ៧.១.ក. ការប្រើប្រាស់បច្ចេកវិទ្យាចាប់សញ្ញាពីចម្ងាយ រួមទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងព័ត៌មានតាមរយៈផ្កាយរណប បច្ចេកវិទ្យាប្រមូលទិន្នន័យនៅនឹងកន្លែង បច្ចេកវិទ្យាប្រមូលទិន្នន័យដែលមានមូលដ្ឋានលើឌីជីថល (ឧទាហរណ៍ទូរសព្ទ ឬថេប្លេត) និងការផ្ទុក ព័ត៌មាននៅលើលម្ហអាកាស ឧបករណ៍ទំនាក់ទំនងឌីជីថល និងកម្មវិធីផ្អែកលើគេហទំព័រ ឬទូរសព្ទ | មាន | ប្រព័ន្ធ PRISM ត្រូវបានបង្កើតឡើងដោយតារាងអេឡិចត្រូនិកដែលមានមូលដ្ឋានលើ KoBo សម្រាប់ការប្រមូលទិន្នន័យក្រោយផលប៉ះពាល់យ៉ាងឆាប់រហ័ស និងផ្ទាំងគ្រប់គ្រងមើលឃើញសម្រាប់របាយការណ៍ពីទីវាល (មានសម្រាប់ NCDM តែប៉ុណ្ណោះ) និងសំណុំទិន្នន័យសកល/មូលដ្ឋានដូចជា NASA-SERVIR, HydraFloods, EWS1294, IDPoor ជាដើម។ CamDi គឺជាមូលដ្ឋានទិន្នន័យឌីជីថលសម្រាប់ការបាត់បង់និងការខូចខាត។ EWS1294 ប្រើឧបករណ៍ចាប់សញ្ញាទឹកទន្លេដែលមានមូលដ្ឋានលើ sonar និងបច្ចេកវិទ្យា IVR សម្រាប់ការផ្សព្វផ្សាយការជូនដំណឹង; ប្រព័ន្ធផ្សាយសារ បច្ចុប្បន្នកំពុងត្រូវបានសាកល្បងដោយ អង្គការ PIN រួមជាមួយ Smart Axiata និង NCDM។ |
| ពហុ | **៨. តើចំណេះដឹងអំពីហានិភ័យបានរួមបញ្ចូលវិមាត្របរិស្ថានដែរឬទេ?** | | | |
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ៨.១. ការវាយតម្លៃ និងបរិមាណនៃផលប៉ះពាល់សត្វ ត្រូវបានធ្វើឡើង និងធ្វើផែនទីសម្រាប់គ្រោះថ្នាក់ពាក់ព័ន្ធ | ៨.១.ក. ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលប្រើដើម្បីរៀបចំផែនទីភាពងាយរងគ្រោះ | មាន | |
| | | ៨.១.ខ. ប្រព័ន្ធការងារស្ថិតិដើម្បីប្រមូល គ្រប់គ្រង និងវិភាគទិន្នន័យស្តីពីភាពងាយរងគ្រោះបរិស្ថាន (បានធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ ឆ្នាំម្តង) | មិនមាន | |
| | | ៨.១.គ. សារពើភណ្ឌនៃប្រភេទសត្វ និងប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ បានធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ឆ្នាំម្តង | មានដោយផ្នែក | អនុសញ្ញាស្តីពីជីវៈចម្រុះ : ប្រវត្តិប្រទេសកម្ពុជាស្តីពីជីវចម្រុះ៖ ស្ថានភាព និងនិន្នាការនៃជីវចម្រុះ រួមទាំងអត្ថប្រយោជន៍ពីជីវចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី។<br>តំណភ្ជាប់ : https://www.cbd.int/countries/profile?country=kh |
| | | ៨.១.ឃ. ផែនទីគ្រោះថ្នាក់ដែលត្រួតពិនិត្យជាមួយទិន្នន័យជីវចម្រុះ | មិនមាន | |

| | | | | |
|---|---|---|---|---|
| លទ្ធផលទី១ : ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ៨.២. ទិន្នន័យអតីតកាលស្តីពីគ្រោះថ្នាក់ និងផលប៉ះពាល់បរិស្ថានត្រូវបានប្រមូល | ៨.២.ក. មូលដ្ឋានទិន្នន័យឌីជីថលនៃទិន្នន័យអតិតកាលស្តីពីផលប៉ះពាល់បរិស្ថាន គ្របដណ្តប់ ២០ឆ្នាំចុងក្រោយ និងបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ | មិនមាន | CamDi បង្ហាញទិន្នន័យអំពីផលប៉ះពាល់ចាប់តាំងពីឆ្នាំ១៩៩៦ ប៉ុន្តែមិនមានព័ត៌មានអំពីផលប៉ះពាល់បរិស្ថានទេ។ |
| លទ្ធផលទី៦ : ILK សម្រាប់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ៨.៣. ចំណេះដឹងក្នុងស្រុក និងជនជាតិដើមភាគតិចស្តីពីភាពងាយរងគ្រោះបរិស្ថានត្រូវបានរួមបញ្ចូលទៅក្នុងការវាយតម្លៃហានិភ័យ | ៨.៣.ក. ការវាយតម្លៃហានិភ័យរួមមានចំណេះដឹងក្នុងស្រុក និងជនជាតិដើមភាគតិចអំពីភាពងាយរងគ្រោះបរិស្ថាន | មាន | ការសិក្សាលើកទី៣ ស្តីពីការស្វែងយល់ពីទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា : ចំណេះដឹង ឥរិយាបថ និងការអនុវត្ត, ឆ្នាំ២០២១ ដោយក្រសួងបរិស្ថាន។ |
| | | ៨.៣.ខ. ប្រព័ន្ធឌីជីថលមាននៅនឹងកន្លែងដើម្បីអនុញ្ញាតឱ្យសហគមន៍ធ្វើការប្រមូល និងរាយការណ៍ទិន្នន័យបរិស្ថាន | មិនមាន | |
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៨.៤. សហគមន៍វិទ្យាសាស្ត្រត្រូវបានចូលរួមសម្រាប់ការវិភាគហានិភ័យបរិស្ថាន និងភាពងាយរងគ្រោះដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ៨.៤.ក. របាយការណ៍វិទ្យាសាស្ត្រ និងអត្ថបទស្តីពីទំនាក់ទំនងអាកាសធាតុ-ជីវចម្រុះត្រូវបានរៀបចំ | មានដោយផ្នែក | ការគាំទ្រផ្អែកលើគម្រោង; សន្ទស្សន៍នៃការអនុវត្តលើបរិស្ថាន (EPI) ឆ្នាំ២០២២។ https://epi.yale.edu/epi-results/2022/country/khm<br><br>CCCA3 បានចូលរួមជាមួយសាកលវិទ្យាល័យក្នុងស្រុកដែលផ្តល់ជំនួយដើម្បីជួយដល់ការស្រាវជ្រាវជាក់លាក់ និងនិស្សិតថ្នាក់បណ្ឌិត ស្តីពីការប្រែប្រួលអាកាសធាតុ។ ទោះបីជាមិនមានអ្វីជាក់លាក់អំពី EWS ត្រូវបានធ្វើឡើងនៅឡើយ កិច្ចសហការដ៏ល្អដែលបានបង្កើតឡើងជាមួយ ITC, RUPP និង NUBB អាចត្រូវបានស្វែងរកបន្ថែមទៀត។ |
| លទ្ធផលទី៣ : ការប្រើប្រាស់ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន | ៨.៥. ហានិភ័យដែលបានកំណត់ត្រូវបានដាក់បញ្ចូលនៅក្នុងផែនការ និងយុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន | ៨.៥.ក. ផែនការ និងយុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន បានគ្របដណ្តប់ដល់គ្រោះថ្នាក់ទាក់ទងនឹងអាកាសធាតុ និងហានិភ័យដែលពាក់ព័ន្ធ | មានដោយផ្នែក | នៅក្នុង CCCSP ចុងក្រោយបំផុត ២០១៣-២៣ ហានិភ័យអាកាសធាតុទូលំទូលាយត្រូវបានកំណត់អត្តសញ្ញាណ។ បន្ទាប់ពីនេះ ផែនការសកម្មភាពអំពីការប្រែប្រួលអាកាសធាតុ ២០១៤-២៨ ត្រូវបានបង្កើតឡើងនៅក្រោមក្រសួងជាង ១០ រួមមានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ធនធានទឹក និងឧតុនិយម, រ៉ែនិងថាមពល, អភិវឌ្ឍន៍ជនបទ, សាធារណការ និងដឹកជញ្ជូន, សុខាភិបាល, ការអប់រំ, និងកិច្ចការនារី ដែលហានិភ័យ និងផលប៉ះពាល់ទាក់ទងនឹងអាកាសធាតុត្រូវបានកំណត់ជាធម្មតា។<br><br>បច្ចុប្បន្នមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSPD) ២០២៤–២៨ និងការធ្វើបច្ចុប្បន្នភាព CCCSP ២០២៤-៣៣ ថ្មី។ |
| លទ្ធផលទី៥ : ការសម្របសម្រួលភាគីពាក់ព័ន្ធ | ៨.៦. ភាពជាដៃគូជាមួយភាគីពាក់ព័ន្ធក្នុងការការពារបរិស្ថានត្រូវបានបង្កើតឡើង ភាគីពាក់ព័ន្ធទាំងនេះបានចូលរួមក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | ៨.៦.ក. ភាគីពាក់ព័ន្ធដែលចូលរួមក្នុងការការពារបរិស្ថានបានចាត់តាំងកាតព្វកិច្ច តួនាទីការទទួលខុសត្រូវ និងមន្ត្រីបង្គោលបច្ចេកទេសលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | មិនមាន | ដំណើរការពិគ្រោះយោបល់លើ NAP-DRR ២០២៤-២៨ បានប្រមូលផ្តុំដៃគូសកម្មជាច្រើន នៅក្នុង DRR និងផ្តោតលើការវិនិយោគដែលត្រូវការក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់ភាពធន់ អភិបាលកិច្ចហានិភ័យ និងបង្កើនការត្រៀមបម្រុង, ការឆ្លើយតប និងការស្តារឡើងវិញ, មិនមែនការការពារបរិស្ថានទេ។ |
| លទ្ធផលទី២ : បើកឱ្យមានការចូលប្រើព័ត៌មានអំពីពីហានិភ័យដោយសេរី | ៨.៧. ការរៀបចំស្ថាប័ន និងសមត្ថភាពបច្ចេកទេសត្រូវបានរៀបចំដើម្បីផ្លាស់ប្តូរទិន្នន័យគ្រោះថ្នាក់បរិស្ថានរវាងភាគីពាក់ព័ន្ធ (NMHS, ទីភ្នាក់ងារបរិស្ថាន) | ៨.៧.ក. ការរៀបចំស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រូវបានរៀបចំដើម្បីអនុញ្ញាតឱ្យមានការចែករំលែកទិន្នន័យរវាងភាគីពាក់ព័ន្ធ | មិនមាន | |

**បញ្ជាក់ :** WMO កំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យសម្រាប់សសរស្តម្ភទី២ ជាមួយសមាជិករបស់ WMO ទាំងអស់ ដែលមានសេវាឧតុនិយម និងជលសាស្ត្រជាតិ។ សូមប្រើឧបករណ៍ស្ទង់មតិនេះសម្រាប់ព័ត៌មានតែប៉ុណ្ណោះ ព្រោះសកម្មភាពបន្ថែមជាមួយសមាជិក WMO អាចជាការស្ទួននៃកិច្ចខិតខំប្រឹងប្រែង។

| ខ្សែចង្វាក់តម្លៃនៃ EWS | # | ឈ្មោះ | សំណួរ | ចម្លើយ | សំណួរដេញបន្ថែម | អាស្រ័យគ្រោះថ្នាក់ | សម្ភារៈធនធាន | មតិយោបល់ |
|---|---|---|---|---|---|---|---|---|
| 0. អន្តរសេសវគ្គ | 0 | គ្រោះថ្នាក់អាទិភាព | តើអ្វីជាគ្រោះថ្នាក់ជាអាទិភាពសម្រាប់ប្រទេសរបស់អ្នក? | ផ្សេងពីការផុតជីវម៉ាស; ភ្លើងឆេះព្រៃ / ភ្លើងឆេះព្រៃ; ខ្យល់ព្យុះកំបុតត្បូង ខ្យល់ព្យុះ / ទឹកជំនន់ឆ្នេរសមុទ្រ | តើគ្រោះថ្នាក់ទាំង៥មានអ្វីខ្លះ? ព្យុះស៊ីក្លូនត្រូពិក, ជំនន់ទឹកទន្លេ, ជំនន់ភ្លាមៗ, ខ្យល់ព្យុះ / ទឹកជំនន់ឆ្នេរសមុទ្រ, រលកកម្តៅ/ គ្រោះរាំងស្ងួត | បាទ/ចាស | | ខ្ញុំសូមផ្តល់យោបល់ឱ្យផ្លាស់ប្តូរ "ការកើនឡើងនៃព្យុះ/ទឹកជំនន់ឆ្នេរសមុទ្រ" ជាមួយនឹង "រន្ទះបាញ់" (ដូចដែលរលកព្យុះកម្រនឹងកើតឡើងនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា) ក៏ដាក់នូវគ្រោះរាំងស្ងួត/ខ្យល់ព្យុះ/រលកកម្តៅផងដែរ។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០១ | ៨.០៧ ច្បាប់គ្រប់គ្រងប្រព័ន្ធប្រកាសឱ្យដឹងមុនចំពោះពហុគ្រោះថ្នាក់ (MHEWS) | នៅក្នុងប្រទេស តើមានច្បាប់ ក្រឹត្យ ឬនីតិប្បញ្ញត្តិផ្សេងទៀត ស្តីពីប្រព័ន្ធប្រកាសឱ្យដឹងមុនចំពោះពហុគ្រោះថ្នាក់ដែរឬទេ? (ឧ. គោលនយោបាយប្រកាសអាសន្នជាតិ) | ច្បាប់; ក្រឹត្យ; ច្បាប់ផ្សេងទៀត; គ្មាន | | ទេ | MOWRAM ត្រូវបានបង្កើតឡើងដោយផ្អែកលើប្រកាស NS/RKM/0699108 ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩; ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំសម្រាប់ធនធានទឹក និងឧតុនិយម។<br>ភាពពាក់ព័ន្ធនៃការប្រកាសឱ្យដឹងមុនអំពីឧតុនិយម-ជលសាស្ត្រ ក៏ត្រូវបានគូសបញ្ជាក់នៅក្នុងគោលនយោបាយ និងផែនការជាតិជាច្រើនទៀត រួមទាំង ប៉ុន្តែមិនកំណត់ចំពោះចំណុចខាងក្រោម ៖<br>- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ ២០១៥<br>- ក្របខ័ណ្ឌកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាតិ ឆ្នាំ២០១៩-២០៣០<br>- ផែនការសកម្មភាពជាតិសម្រាប់ DRR (NAP-DRR) ឆ្នាំ២០១៩-២០២៣ និងឆ្នាំ២០២៤-២៨<br>- NAP-DRR ២០១៤-២០១៨ និង SNAP DRR ២០០៨-២០១៣<br>- ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣<br>- ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម ឆ្នាំ ២០១៤-២០១៨ និងផែនការសកម្មភាពបម្រែបម្រួលអាកាសធាតុសម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ២០១៤-២០១៨<br>- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣<br>- NSDP ២០១៤-២០១៨ | MOWRAM ត្រូវបានបង្កើតឡើងដោយផ្អែកលើ ប្រកាសលេខ នស/រកម/០៦៩៩១០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩៩។ ភារកិច្ច និងទំនួលខុសត្រូវរបស់ក្រសួងរួមមានដូចខាងក្រោម៖<br>បង្កើតទីតាំងនយោបាយ និងយុទ្ធសាស្ត្រទាក់ទងនឹងភាពអាចរកបានធនធានទឹកសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងនិរន្តរភាពរបស់វានៅកម្រិតជាតិ និងអន្តរជាតិ។ អនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រលើសក្តានុពលនៃធនធានទឹកក្រោមដី និងផ្ទៃទឹក; កំណត់ទិសដៅ និងផែនទីបង្ហាញផ្លូវក្នុងរយៈពេលខ្លី មធ្យម និងវែង ទាក់ទងនឹងការប្រើប្រាស់ទឹក ដើម្បីបំពេញតម្រូវការសម្រាប់ការអភិវឌ្ឍប្រទេស។ ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់ទឹក ដើម្បីកាត់បន្ថយហានិភ័យ។ រៀបចំ និងតាក់តែងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រើប្រាស់ និងការគ្រប់គ្រងទឹក។ ប្រមូលឯកសារ និងទិន្នន័យបច្ចេកទេស/ការស្រាវជ្រាវអំពីអាកាសធាតុ និងជលសាស្ត្រ ព្រមទាំងការប្រើប្រាស់ទឹកផងដែរ។<br>ផ្តល់ជំបូន្មានបច្ចេកទេសដល់ និងលើកកម្ពស់ចំណេះដឹងរបស់ ឧស្សាហកម្ម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងប្រជាជនអំពីការអភិវឌ្ឍ និងការប្រើប្រាស់ធនធានទឹក។ ទំនាក់ទំនង និងកាលើកកម្ពស់បច្ចេកទេសប្រកបដោយភាពច្នៃប្រឌិតលើការសម្អាត និងការប្រើប្រាស់ទឹក; សហការ និងចូលរួមក្នុងការគ្រប់គ្រងអាងទន្លេមេគង្គ ក្នុងការគ្រប់គ្រងធនធានទឹក ក៏ដូចជាផ្នែកឧតុនិយម។<br>ក្រសួងតែងតែគូសបញ្ជាក់អំពីវឌ្ឍនភាពរយៈពេលមធ្យមរបស់ខ្លួន ក៏ដូចជាផែនការនៅក្នុងផែនការយុទ្ធសាស្ត្រប្រាំឆ្នាំរបស់ខ្លួនសម្រាប់ធនធានទឹក និងឧតុនិយម ដែលចុងក្រោយបំផុតសម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ នៅក្នុងឯកសារ ក្រសួងធនធានទឹកបានកំណត់សមិទ្ធផលសម្រាប់ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក៏ដូចជាផែនការសម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។<br>ទោះជាយ៉ាងណា រហូតមកដល់បច្ចុប្បន្ន មិនមានគោលនយោបាយ យុទ្ធសាស្ត្រ ឬផែនការសកម្មភាពជាក់លាក់ណាមួយ ដែលជួយណែនាំ DOM និង DHRW លើផ្នែកដូចជា៖ i) ការកែលម្អបណ្តាញធារាសាស្ត្រ ពង្រីក និងថែទាំ ii) គោលនយោបាយទិន្នន័យអ៊ីរ៉ូមេន។ iii) ការអភិវឌ្ឍធនធានមនុស្ស iv) ការត្រួតពិនិត្យ ការព្យាករ និងការបកស្រាយសម្រាប់អ្នកប្រើប្រាស់ និង v) ការកៀរគរធនធាន និងនិរន្តរភាពហិរញ្ញវត្ថុដែលនឹងធានាបាននូវនិរន្តរភាព និងប្រសិទ្ធភាពនៃការផ្តល់ការព្រមានជាមុន និងអាកាសធាតុ។ សេវាកម្មដល់វិស័យអាទិភាព។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០២ | និតិវិធីស្តង់ដា និងតួនាទីដែលត្រូវបានបង្កើតឡើងក្នុងចំណោមភ្នាក់ងារប្រកាសអាសន្ន | តើ**តួនាទី** និង**ទំនួលខុសត្រូវ**របស់អង្គការទាំងអស់ដែលបង្កើត និងចេញការប្រកាសអាសន្នត្រូវបានបង្កើតឡើង និងកំណត់ដោយច្បាប់ ឬឧបករណ៍គតិយុទ្ធផ្សេងទៀតដែរឬទេ? | បាទ/ចាស | | បាទ/ចាស | | |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០៣ | ៨.០៤ គណៈកម្មាធិការជាតិ ឬវេទិកាដែលមានសមាសភាពពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ដែលសម្របសម្រួលសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ | តើមានគណៈកម្មាធិការជាតិ ឬវេទិកាដែលមានសមាសភាពពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលសម្របសម្រួលសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិដែរឬទេ? | បាទ/ចាស | | ទេ | ការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ | ស្ថាប័នដែលត្រូវបានចាត់តាំងថ្នាក់ជាតិខ្ពស់បំផុតសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា គឺគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាមួយនឹងអាណត្តិនៃការសម្របសម្រួលការឆ្លើយតបច្រើនក្រសួងចំពោះព្រឹត្តិការណ៍សង្គ្រោះបន្ទាន់ និងគ្រោះមហន្តរាយ។<br>គ.ជ.គ.ម. មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយដែលត្រូវការដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ ឬដែលបង្កើតឡើងដោយមនុស្សនៅក្នុងប្រទេសកម្ពុជា។ គ.ជ.គ.ម. ទទួលខុសត្រូវលើការចេញគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទប្បញ្ញត្តិ ការណែនាំ កម្មវិធី និងគម្រោងនៅទូទាំងខ្សែចង្វាក់នៃការគ្រប់គ្រងគ្រោះមហន្តរាយពីការបង្ការ កាត់បន្ថយ ការត្រៀមបម្រុង ការឆ្លើយតបបន្ទាន់ និងការស្តារឡើងវិញ។ បន្ទាប់ពី គ.ជ.គ.ម. គណៈកម្មាធិការត្រូវបានបង្កើតឡើងនៅថ្នាក់ក្រោម |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ជាតិ និងថ្នាក់មូលដ្ឋាន រួមមានគណៈកម្មាធិការ ការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត(PCDM) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក (DCDM) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំ (CCDM)។ នៅតំបន់ខ្លះ ក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ (VDMG) ក៏ត្រូវបានបង្កើតឡើងក្រោម CCDM ផងដែរ។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០៤ | ៨.០៥ សមាជិកភាព NMS នៅក្នុងយន្តការនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាតិ | បាទ/ចា, តើ NMS របស់អ្នកជាសមាជិកដែរឬទេ? | បាទ/ចាស | | ទេ | N/A | គ.ជ.គ.ម. ជួបប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ហើយអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន វិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះ និងធ្វើការស្រាវជ្រាវលើបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។ ជាពិសេស នាយកដ្ឋានឧតុនិយម (DOM) និងនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ (DHRW) ព្រោះ MOWRAM ជាក្រសួងមានកាតព្វកិច្ចផ្តល់ការប្រកាសអាសន្ន និងការណែនាំអំពីការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០៥ | NMHS ត្រូវបានទទួលស្គាល់ជាផ្លូវការថាជាអាជ្ញាធរទទួលបន្ទុកលើការប្រកាសអាសន្នរបស់ជាតិ | តើ NMHS របស់អ្នកត្រូវបានទទួលស្គាល់ជាផ្លូវការថាជាអាជ្ញាធរទទួលបន្ទុកលើការប្រកាសអាសន្នរបស់ជាតិសម្រាប់គ្រោះថ្នាក់ដោយឧតុនិយមនៅក្នុងប្រទេស របស់អ្នកដែរឬទេ? | បាទ/ចាស | | បាទ/ចាស | N/A | DOM ទទួលខុសត្រូវចំពោះការអង្កេតឧតុនិយមទាំងអស់ និងជាអ្នកចេញការព្យាករជាតុអាកាស ផលិតផលព័ត៌មានអាកាសធាតុ និងការប្រកាសអាសន្នអំពីអាកាសធាតុធ្ងន់ធ្ងរ ដើម្បីគាំទ្រការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ DOM ផ្តល់សេវាកម្មអាកាសធាតុសម្រាប់វិស័យផ្លូវថ្នល់ និងផ្លូវដែក ទេសចរណ៍ សមុទ្រ និងវិស័យផ្សេងៗទៀត។ ម្យ៉ាងវិញទៀត DHRW ក្សោ និងតាមដានស្ថានីយជលសាស្ត្រតាមប្រព័ន្ធទន្លេនៃប្រទេសកម្ពុជា។ DHRW ក៏ទទួលខុសត្រូវលើការព្យាករទឹកជំនន់ និងសម្រាប់ការចេញការព្យាករកម្ពស់ទឹកសម្រាប់ទន្លេមេគង្គ និងប្រព័ន្ធបឹងទន្លេសាប (MOWRAM, ២០១៧)។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០៦ | កិច្ចព្រមព្រៀង និងពិធីការអន្តរទំនាក់ទំនង ដែលបានបង្កើតឡើងសម្រាប់ការចែករំលែកទិន្នន័យនៃប្រព័ន្ធត្រួតពិនិត្យ និងទិន្នន័យមូលដ្ឋានដែលចាំបាច់សម្រាប់រៀបចំផលិតផលទិន្នន័យ (ឧ. ទិន្នន័យសណ្ឋានដីសម្រាប់ការបង្កើតម៉ូដែលលេកយក្សស៊ូណាមិ) សម្រាប់គ្រោះថ្នាក់ជាអាទិភាពទាំងអស់ | តើកិច្ចព្រមព្រៀង និងពិធីសារស្តីពីអន្តរទំនាក់ទំនងត្រូវបានបង្កើតឡើងសម្រាប់ចែករំលែកទិន្នន័យនៃប្រព័ន្ធត្រួតពិនិត្យ និងទិន្នន័យមូលដ្ឋានចាំបាច់ដើម្បីផលិតផលិតផលទិន្នន័យសម្រាប់គ្រោះថ្នាក់ជាអាទិភាពទាំងអស់ដែរឬទេ? | ទេ | | ទេ | N/A | មិនមានគោលការណ៍ចែករំលែកទិន្នន័យច្បាស់លាស់រវាង MOWRAM និងភ្នាក់ងារតាមវិស័យទេ។ សម្រាប់ការរៀបចំកម្រិតមធ្យមដល់រយៈពេលវែង ក្រសួង និងទីស្ថាប័នពាក់ព័ន្ធអាចបន្ត MoU ឬលិខិតកិច្ចព្រមព្រៀងជាមួយ MOWRAM សម្រាប់ការចែករំលែកទិន្នន័យ។ |
| **ក. អភិបាលកិច្ច ការគ្រប់គ្រង និងយន្តការស្ថាប័ន** | ក.០៧ | ការផ្លាស់ប្តូរការប្រកាសអាសន្នឆ្លងព្រំដែនជាមួយប្រទេសជិតខាង សម្រេចបានតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី/ពហុភាគីសម្រាប់គ្រោះថ្នាក់ជាអាទិភាពទាំងអស់ | តើការផ្លាស់ប្តូរការប្រកាសអាសន្នឆ្លងព្រំដែនជាមួយប្រទេសជិតខាងត្រូវបានសម្រេចតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី/ពហុភាគីដែរឬទេ? | បាទ/ចាស | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | មជ្ឈមណ្ឌលព្យាករណ៍ជំនួយក្នុងតំបន់, នៅទីក្រុងហាណូយ<br><br>គណៈកម្មការទន្លេមេគង្គ | DOM និង DHRW (ជា NMHS) សហការជាមួយតំបន់មេគង្គសម្រាប់ការចែករំលែកទិន្នន័យ និងផលិតផលជលសាស្ត្រ-ឧតុនិយម។ នៅក្រោមគម្រោងបង្ហាញការព្យាករណ៍របស់ WMO, DOM ទទួលបានផលិតផល NWP និងការគាំទ្រទាក់ទងនឹងការចែករំលែកទិន្នន័យ ការពង្រឹងសមត្ថភាពព្យាករណ៍ និងការបណ្តុះបណ្តាលបុគ្គលិក។ |
| **ខ. សមត្ថភាពសង្កេតឃ្លាំមើល** | ខ.០១ | គម្លាតទិន្នន័យធំ | តើមានតំបន់ក្នុងប្រទេសដែលមិនមានការសង្កេតដែរឬទេ (ឧ. ដោយសារហេតុផលភូមិសាស្ត្រនយោបាយ ឬហេតុផលផ្សេងទៀត)? | បាទ/ចាស | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | N/A | មិនមានស្ថានីយជលសាស្ត្រស្វ័យប្រវត្តិក្នុងខេត្តរតនគិរី មណ្ឌលគិរី ត្បូងឃ្មុំ និងស្វាយរៀងទេ។ DHRW មានគោលបំណងបង្កើនស្ថានីយជលសាស្ត្រចំនួនពី៨០ ទៅ៤០០ ដើម្បីគ្របដណ្តប់អាងទន្លេរបស់ប្រទេស។ មានគម្រោងសម្របសម្រួលជាមួយ PDOWRAM សម្រាប់ស្ថានីយបន្ថែមដែលបានស្នើឡើង ប៉ុន្តែ DHRW ពឹងផ្អែកខ្លាំងលើម្ចាស់ជំនួយ និងដៃគូអនុវត្តក្នុងការផ្តល់មូលនិធិសម្រាប់ការចំណាយវិនិយោគលើការដំឡើងស្ថានីយថ្មី។ បច្ចុប្បន្ន DOM ដំណើរការ ស្ថានីយឧតុនិយមស្វ័យប្រវត្តិ (AWS) ចំនួន៨៦ ហើយគ្រោងនឹងបង្កើនវាហូតដល់មួយក្នុងឃុំ-សង្កាត់នីមួយៗ (សរុបប្រហែល១៧០ស្ថានីយ)។ |
| **ខ. សមត្ថភាពសង្កេតឃ្លាំមើល** | ខ.០២ | កម្រិតច្បាស់នៃការគ្របដណ្តប់ជាមធ្យមគិតជាគីឡូម៉ែត្រនៃផ្ទៃ និងការអង្កេតលើអាកាស | តើស្ថានីយសង្កេតលើផ្ទៃចំនួនប៉ុន្មានដែល NMHS របស់អ្នកដំណើរការ? | (៨៦ ស្ថានីយឧតុនិយមស្វ័យប្រវត្តិ, ២៣៨ ឧបករណ៍វាស់ទឹកភ្លៀងដោយដៃ) | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតឃ្លាំមើល** | ខ.១៦ | | ស្ថានីយលើផ្ទៃដែលត្រូវស្តង់ដារបស់ WIGOS? | ១៥ ត្រូវតាមស្តង់ដារបស់ WIGOS និង រាយការណ៍ទៅ GTS | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតឃ្លាំមើល** | ខ.០៣ | ប្រេកង់ពេលវេលានៃការសង្កេតលើផ្ទៃ | តើប្រេកង់ពេលវេលានៃការសង្កេតផ្ទៃប៉ុន្មានដែរ? | រាល់ម៉ោង | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតឃ្លាំមើល** | ខ.០៤ | ការសង្កេតខ្យល់ខាងលើដែលបានវាស់ | តើស្ថានីយអង្កេតលើអាកាសប៉ុន្មានដែល NMHS របស់អ្នកដំណើរការនៅក្នុងប្រទេស? | មិនមាន | | ទេ | N/A | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.០៥ | ប្រេកង់ពេលវេលានៃការសង្កេតខ្យល់ខាងលើ | ប្រសិនបើការសង្កេតខ្យល់ខាងលើត្រូវបានធ្វើឡើង តើមានប្រេកង់ពេលវេលារបស់វាប៉ុន្មានដែរ? | N/A | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.០៦ | ស្ថានីយដែលមិនដំណើរការ | តើចំនួន (ឬភាគរយ) នៃស្ថានីយបច្ចុប្បន្នមិនអាចដំណើរការនៅក្នុងប្រទេសមានប៉ុន្មាន? | ៣៥ ស្ថានីយឧតុនិយម, ៨០ ស្ថានីយជលសាស្ត្រ (កម្ពស់ទឹក) | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.០៧ | ភាគរយនៃការសង្កេតលើផ្ទៃដែលអាស្រ័យលើបច្ចេកទេសស្វ័យប្រវត្តិ | តើភាគរយប៉ុន្មាននៃបណ្តាញសង្កេតរបស់អ្នក ដែលបានដំណើរការដោយស្វ័យប្រវត្តិ? | DOM : ៣៦%, DHRW : ៧០% | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.០៨ | ស្ថានីយស្វ័យប្រវត្តិថ្មីដែលត្រូវបានប្រើក្នុងរយៈពេល៥ឆ្នាំចុងក្រោយ | ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តើស្ថានីយអាកាសធាតុស្វ័យប្រវត្តិថ្មីចំនួនប៉ុន្មាន ត្រូវបានប្រើប្រាស់? | ២៧ ស្ថានីយ | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.១០ | ភាពអាចរកបានទិន្នន័យជិតពេលជាក់ស្តែង (near-real-time) | តើទិន្នន័យអង្កេតដែលទទួលបានជិតជាក់ស្តែង ត្រូវបានបញ្ជូននៅទៅមជ្ឈមណ្ឌលឧតុនិយមជាតិ ដែរឬទេ? | បាទ/ចាស (សម្រាប់ស្ថានីយស្វ័យប្រវត្តិ) | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.១១ | ការពិនិត្យផ្ទៀងផ្ទាត់ទៀងទាត់ និងថែទាំប្រព័ន្ធសង្កេត | តើ NMHS របស់អ្នកមានសមត្ថភាពដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ ការត្រួតពិនិត្យគុណភាព និងការថែទាំប្រព័ន្ធសង្កេតដែលកំពុងដំណើរការដែរឬទេ? | មានផ្នែកខ្លះ; ទេ | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.១២ | ការរៀបចំជាមួយមជ្ឈមណ្ឌលឧបករណ៍ក្នុងតំបន់ (RIC) | តើមានការរៀបចំជាមួយមជ្ឈមណ្ឌលឧបករណ៍ប្រចាំតំបន់ (RIC) ដើម្បីជួយអ្នកក្នុងការផ្ទៀងផ្ទាត់តាមខ្នាតស្ថានីយសង្កេតរបស់អ្នកដែរឬទេ? | ទេ | | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.១៤ | ប្រភពទិន្នន័យសង្កេតផ្សេងទៀត | តើអ្នកទទួល/ប្រើទិន្នន័យសង្កេតពីប្រភពទិន្នន័យផ្សេងទៀត ឧ. ពីទីស្ថាប័នរដ្ឋាភិបាលផ្សេងទៀត គម្រោងស្រាវជ្រាវ ឬវិស័យឯកជនដែរឬទេ? | ទេ | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | N/A | |
| **ខ. សមត្ថភាពសង្កេតទូទៅ** | ខ.១៥ | ៥.២០ ការសង្កេតមិនត្រូវបានបញ្ជូនទៅ GTS/WIS នោះទេ | តើ NMHS របស់អ្នកមានការសង្កេត ដែលមិនត្រូវបានបញ្ជូនទៅ GTS/WIS សម្រាប់គោលបំណងផ្ទាល់ខ្លួនរបស់អ្នកទេ? | បាទ/ចាស | | ទេ | N/A | |
| **គ. ការសង្កេតគ្រោះថ្នាក់ជាក់លាក់** | គ.០១ | សមត្ថភាពសង្កេតគ្រប់គ្រាន់ | តើអ្នកនឹងវាយតម្លៃភាពគ្រប់គ្រាន់នៃសមត្ថភាពសង្កេតបច្ចុប្បន្នលើ NMHS របស់អ្នកយ៉ាងដូចម្តេច ដើម្បីតាមដានគ្រោះថ្នាក់ញឹកញាប់បំផុត និងផលប៉ះពាល់ដែលប៉ះពាល់ដល់ប្រទេសរបស់អ្នក? | ៣-មធ្យម; គម្លាតនៃការសង្កេតមួយចំនួន និងបញ្ហាគុណភាពទិន្នន័យ ការចូលប្រើប្រាស់មានកំណត់ចំពោះផលិតផលចាប់សញ្ញាពីចម្ងាយ និងទិន្នន័យផ្សេងទៀត ការគ្របដណ្តប់ទិន្នន័យកម្រិតមធ្យម ការដោះស្រាយបណ្តោះអាសន្ន និងទំហំសម្រាប់គ្រោះថ្នាក់ជាអាទិភាពនីមួយៗ | | បាទ/ចាស | N/A | ដោយផ្អែកលើព័ត៌មានដែល WMO មាន (៣-មធ្យម); គម្លាតនៃការសង្កេតមួយចំនួន និងបញ្ហាគុណភាពទិន្នន័យ ការចូលប្រើប្រាស់មានកំណត់ចំពោះផលិតផលចាប់សញ្ញាពីចម្ងាយ និងទិន្នន័យផ្សេងទៀត វិសាលភាពគ្របដណ្តប់នៃទិន្នន័យកម្រិតមធ្យម កម្រិតភាពច្បាស់ទាំងចន្លោះពេលវេលា និងទំហំសម្រាប់គ្រោះថ្នាក់ជាអាទិភាពនីមួយៗ ។ ទោះបីជាមានការដាក់ទុនច្រើន ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏ MOWRAM ជួបប្រទះបញ្ហាប្រឈមជាមួយនឹងបណ្តាញសង្កេតរបស់ខ្លួន សូមមើលខាងក្រោម៖<br>ដោយសារតែការវិនិយោគតិចតួចពីម្ចាស់ជំនួយ និងដៃគូអនុវត្តផ្សេងៗគ្នា DOM ប្រឈមមុខនឹងបញ្ហាជាច្រើននៅក្នុងបណ្តាញសង្កេត និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទិន្នន័យរបស់ខ្លួន។ ឧទាហរណ៍ ការដំឡើងម៉ាកឧបករណ៍ និងឧបករណ៍ជំនួយផ្សេងៗគ្នាពីគម្រោងចំនួនបី មានន័យថាបុគ្គលិក DOM ត្រូវការទទួលការបណ្តុះបណ្តាលក្នុងប្រតិបត្តិការ និងថែទាំប្រព័ន្ធយ៉ាងហោចណាស់បីផ្សេងគ្នា។ បន្ថែមពីលើបញ្ហាប្រឈមនេះ បុគ្គលិកចំនួន១២នាក់នៅក្នុងការិយាល័យបរិក្ខារ នៅមានការយល់ដឹងតិចតួចលើភាសាអង់គ្លេស។ អ្នកដំឡើងបរិក្ខារ និងការបណ្តុះបណ្តាលភាគច្រើនលើប្រតិបត្តិការ និងការថែទាំឧបករណ៍ ត្រូវបានផ្តល់ជូនជាភាសាអង់គ្លេស។ ម្យ៉ាងវិញទៀត DHRW រក្សាម៉ាកយីហោស្ថានីយតែមួយគត់ ដូច្នេះមិនមានបញ្ហាប្រឈមដូច DOM នៅពេលនិយាយអំពីប្រតិបត្តិការ និងការថែទាំ ក៏ដូចជាភាពត្រូវគ្នា និងអន្តរប្រតិបត្តិការនៃប្រព័ន្ធ និងទិន្នន័យ។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ទាំង DOM និង DHRW មានចំនួន គ្រឿងបន្លាស់ឧបករណ៍ចាប់សញ្ញាតិចតួច និងផ្នែកជំនួសផ្សេងទៀតដែលបានទិញរួមគ្នាជាមួយនឹងការទិញស្ថានីយថ្មី។ ប៉ុន្តែនៅពេលដែលគ្រឿងបន្លាស់ទាំងនេះត្រូវបានប្រើប្រាស់អស់ វាពិតជាពិបាកក្នុងការទទួលបានបន្ថែមទៀត។<br>ថវិកាដែលអាចរកបានតិចតួចសម្រាប់គាំទ្រសកម្មភាពថែទាំជាប្រចាំរបស់ស្ថានីយ ដែលទាមទារការទិញគ្រឿងបន្លាស់ និងថ្លៃធ្វើដំណើរ និងការស្នាក់នៅ របស់បុគ្គលិកពីរាជធានីភ្នំពេញ។ DOM និង DHRW បានបង្ហាញថាបុគ្គលិកនៅថ្នាក់ខេត្ត នៅក្នុងការិយាល័យជលសាស្ត្ររបស់ PDoWRAM មានការយល់ដឹង លើប្រតិបត្តិការ និងការថែទាំឧបករណ៍មានកម្រិត។ ដូច្នេះ មានការពិបាកសម្រាប់ពួកគេក្នុងការជួយដោះស្រាយបញ្ហា និងជួសជុល។ សកម្មភាពថែទាំស្ថានីយជលសាស្ត្រ ធ្វើឡើងដោយបុគ្គលិក DHRW ពីរាជធានីភ្នំពេញ។ សម្រាប់ DOM, ប្រតិបត្តិការ និងការថែទាំ AWS បច្ចុប្បន្នត្រូវបានអនុវត្តដោយបុគ្គលិក IT ចំនួន២នាក់ ដែលបានស្គាល់ប្រព័ន្ធ។ ពួកគេអាចពិនិត្យស្ថានីយពីចម្ងាយ ហើយនៅពេលដែលមានបញ្ហា ពួកគេទាក់ទងទៅអ្នកផ្គត់ផ្គង់/អ្នកផលិតសម្រាប់ការជួសជុលនៅនឹងទីកន្លែង។<br>ទាំង DOM និង DHRW មិនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមគ្នាទេ។ លើសពីនេះទៀត DOM មិនមានមូលដ្ឋានទិន្នន័យរួមបញ្ចូលគ្នាទេ។ ទិន្នន័យពីប្រព័ន្ធ SUTRON, ADCON, WEATHEX និងទិន្នន័យមកពីស្ថានីយដោយដៃត្រូវបានរក្សាទុកក្នុងប្រព័ន្ធទិន្នន័យដាច់ដោយឡែក ហើយអាចត្រូវបានមើលក្នុងវេទិកាផ្សេងៗគ្នា។ |
| **គ. ការសង្កេតគ្រោះថ្នាក់ជាក់លាក់** | ឃ.០៣ | | តើអថេរមួយណាដែលអ្នកតាមដានសម្រាប់គ្រោះថ្នាក់នីមួយៗ? | ព្យុះស៊ីក្លូនត្រូពិក - ខ្យល់, សម្ពាធ, ទឹកភ្លៀង; ទឹកជំនន់ទន្លេ - ទឹកភ្លៀង; ទឹកជំនន់ភ្លាមៗ - ទឹកភ្លៀង; ខ្យល់ព្យុះ / ទឹកជំនន់ឆ្នេរសមុទ្រ - ទឹកភ្លៀងខ្យល់; គ្រោះរាំងស្ងួត / រលកកម្តៅ - ទឹកភ្លៀង សីតុណ្ហភាព ការហួត | | បាទ/ចាស | ការវាយតម្លៃរហ័សរបស់ EW4All | |
| **គ. ការសង្កេតគ្រោះថ្នាក់ជាក់លាក់** | គ.០២ | | តើអ្វីជាគម្លាតសំខាន់នៅក្នុងសមត្ថភាពរបស់ NMHS របស់អ្នកក្នុងការត្រួតពិនិត្យគ្រោះថ្នាក់ជាអាទិភាពនៅក្នុងប្រទេស? | កង្វះស្ថានីយសង្កេត; ស្វ័យប្រវត្តិកម្មមិនគ្រប់គ្រាន់នៃបណ្តាញសង្កេត; មិនគ្រប់គ្រាន់ ការចូលប្រើពេលវេលាជាក់ស្តែង(ជិតជាក់ស្តែង) ចំពោះទិន្នន័យសង្កេត; កង្វះទិន្នន័យការចាប់សញ្ញាពីចម្ងាយ; ការគ្រប់គ្រងគុណភាពទិន្នន័យមិនគ្រប់គ្រាន់; កង្វះនៃសមត្ថភាពត្រួតពិនិត្យនៃអថេរបន្ថែម; ដំណើរការទិន្នន័យមិនគ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធផ្ទុក និងផ្សេងៗទៀត។ | ប្រសិនបើអ្នកជ្រើសរើស "ផ្សេងទៀត" សូមបញ្ជាក់ | បាទ/ចាស | ការវាយតម្លៃរហ័សរបស់ EW4All | |
| **គ. ការសង្កេតគ្រោះថ្នាក់ជាក់លាក់** | គ.០៤ | | តើអថេរបន្ថែមអ្វីខ្លះដែលអ្នកត្រូវតាមដានសម្រាប់គ្រោះថ្នាក់ជាក់លាក់ទាំងនេះ, ប្រសិនបើមាន? | ទិន្នន័យចាប់សញ្ញាពីចម្ងាយ; ការហូរចូលនៃទឹកប្រៃ; សំណើមដី; ឧបករណ៍ចាប់សញ្ញាផ្លេកបន្ទោរ ប៊ូយ រង្វាស់ជំនោរ កម្ពស់រលក ប្រវែងប្រេកង់។ល។ ប៉ារ៉ាម៉ែត្រមួយចំនួនសម្រាប់វិស័យផ្សេងទៀតដូចជាកសិកម្ម អាកាសចរណ៍ នាវាចរណ៍សមុទ្រ ឧស្សាហកម្មជាដើម។ | | បាទ/ចាស | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឃ. ទិន្នន័យពីផ្កាយរណប** | ឃ.០១ | ការប្រើប្រាស់ទិន្នន័យផ្កាយរណប ដើម្បីតាមដានគ្រោះថ្នាក់ | តើ NMHS របស់អ្នកកំពុងប្រើប្រាស់ទិន្នន័យផ្កាយរណប ដើម្បីតាមដានគ្រោះថ្នាក់ជាអាទិភាពនៅក្នុងប្រទេស ដែរឬទេ? | បាទ/ចាស | | បាទ/ចាស | ការវាយតម្លៃរហ័សរបស់ EW4All | ការសង្កេតលើពពក និងទឹកភ្លៀង (ផ្កាយរណបជប៉ុន និងផ្កាយរណបកូរ៉េ) |
| **ឃ. ទិន្នន័យពីផ្កាយរណប** | ឃ.០២ | ស្ថានីយទទួលទិន្នន័យផ្កាយរណបដែលដំណើរការនៅក្នុង NMHS ឬមធ្យោបាយផ្សេងទៀតនៃការចូលប្រើទិន្នន័យផ្កាយរណបដែលបានប្រើ (ឧ. អ៊ីនធឺណិត) | តើអ្នកប្រើមធ្យោបាយអ្វីដើម្បីចូលប្រើទិន្នន័យផ្កាយរណប? | ស្ថានីយទទួលផ្កាយរណប; អ៊ីនធឺណិត | បើ ផ្សេងៗ, សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ឃ. ទិន្នន័យពីផ្កាយរណប** | ឃ.០៣ | បុគ្គលិកបានបណ្តុះបណ្តាលលើការចូលប្រើ និងប្រើប្រាស់ទិន្នន័យពីចម្ងាយ | តើបុគ្គលិក NMHS បានទទួលការបណ្តុះបណ្តាលលើការចូលប្រើ និងការបកស្រាយទិន្នន័យពីចម្ងាយដែរឬទេ? | បាទ/ចាស | | បាទ/ចាស | ការវាយតម្លៃហើសរបស់ EW4All | បាទ, សម្រាប់ទឹកជំនន់ភ្លាមៗ ជំនន់ទឹកទន្លេ និងព្យុះស៊ីក្លូនត្រូពិកតែប៉ុណ្ណោះ |
| **ឃ. ទិន្នន័យពីផ្កាយរណប** | ឃ.០៤ | ការប្រើប្រាស់ទិន្នន័យរ៉ាដា ដើម្បីតាមដានគ្រោះថ្នាក់ | តើ NMHS របស់អ្នកកំពុងប្រើប្រាស់ទិន្នន័យរ៉ាដា ដើម្បីតាមដានគ្រោះថ្នាក់ជាអាទិភាពនៅក្នុងប្រទេស ឬទឹកដីរបស់អ្នកទេ? | បាទ/ចាស | | ទេ | ការវាយតម្លៃហើសរបស់ EW4All | រ៉ាដា ១ស្ថានីយ នៅភ្នំពេញ |
| **ង. ការចែករំលែក និងការគ្រប់គ្រងទិន្នន័យ** | ង.០១ | ការសង្គ្រោះទិន្នន័យត្រូវបានអនុវត្តនៅគ្រប់អថេរ និងកំណត់ត្រាដែលមាន | តើការសង្គ្រោះទិន្នន័យត្រូវបានអនុវត្តនៅគ្រប់អថេរ និងកំណត់ត្រាដែលអាចរកបានដើម្បីអនុញ្ញាតឱ្យកំណត់អត្តសញ្ញាណនៃគ្រោះថ្នាក់អាកាសធាតុ និងអាកាសធាតុស៊េរីរយៈពេលយូរដែរឬទេ? | បាទ/ចាស, ដោយផ្នែក | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |
| **ង. ការចែករំលែក និងការគ្រប់គ្រងទិន្នន័យ** | ង.០២ | ៥.០៨ ការចូលប្រើ NMS ទៅកាន់ផលិតផលដែលផ្តល់ដោយមជ្ឈមណ្ឌលពិភពលោក និងតំបន់របស់ WMO | តើអ្នកនឹងចាត់ថ្នាក់ការចូលប្រើ NMHS របស់អ្នកចំពោះផលិតផលដែលផ្តល់ដោយមជ្ឈមណ្ឌលសកល និងតំបន់របស់ WMO យ៉ាងដូចម្តេច? | អាចប្រើបានក្នុងកម្រិតទុកចិត្តខ្ពស់ | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០១ | Deterministic NWP | តើអ្នកបញ្ចេញការព្យាករ និងការព្រមានដោយផ្អែកលើ NWP កំណត់ទេ? | បាទ/ចាស | បើ បាទ/ចាស, សូមបញ្ជាក់ តើម៉ូដែលណាដែលអ្នកប្រើ? | ទេ | ការវាយតម្លៃហើសរបស់ EW4All | ការចូលប្រើ ARPEGE Model, ផលិតផលមានកំណត់ ការចូលប្រើ NOAA-GFS, GSM (JMA) |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០២ | Probabilistic NWP | តើអ្នកចេញការព្យាករ និងការប្រកាសអាសន្នដោយផ្អែកលើប្រូបាប៊ីលីតេ NWP ទេ? | ទេ | បើ បាទ/ចាស, សូមបញ្ជាក់ តើម៉ូដែលណាដែលអ្នកប្រើ? | ទេ | ការវាយតម្លៃហើសរបស់ EW4All | ការចូលប្រើប្រាស់ផលិតផលមានកម្រិតទៅកាន់ផលិតផលមជ្ឈមណ្ឌលអាកាសធាតុតូក្យូសម្រាប់ការព្យាករ DoM ចេញផ្សាយតែការព្យាករកំណត់ដោយផ្អែកលើជំនាញវិភាគអ្នកព្យាករណ៍ |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៣ | ៥.៩៩ NWP និងផលិតផល ESP | តើ NMS របស់អ្នកមានសមត្ថភាពក្នុងការព្យាករអាកាសធាតុក្រោយដំណើរការជាលេខ (NWP) រួមទាំងផលិតផល Ensemble Prediction System (EPS) ដែរឬទេ? | បាទ/ចាស, សមត្ថភាពមានកម្រិត | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៤ | ៦.១៧ ការចូលប្រើផលិតផលព្យាករណ៍ពី WMCs/RSMCs | តើអ្នកប្រើផលិតផលព្យាករណ៍ពីមជ្ឈមណ្ឌលឧតុនិយមពិភពលោក (WMCs) / មជ្ឈមណ្ឌលឧតុនិយមឯកទេសក្នុងតំបន់ (RSMCs) រួមទាំងមជ្ឈមណ្ឌលអាកាសធាតុក្នុងតំបន់ (RCCs) ដើម្បីជួយក្នុងការផ្តល់សេវារបស់អ្នកដែរឬទេ? (មជ្ឈមណ្ឌលពាក់ព័ន្ធគឺ TBD ក្នុងមួយសមាជិក) | បាទ/ចាស | | ទេ | ការវាយតម្លៃហើសរបស់ EW4All | DoM បានប្រើព័ត៌មានដែលបានផ្តល់ពីគេហទំព័ររបស់ពួកគេ មិនមានការផ្ទេរទិន្នន័យដោយផ្ទាល់ទៅម៉ាស៊ីនមេរបស់យើងទេ។ លើកលែងតែទិន្នន័យពី ARPEGE, GSM, NOAA-GFS |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៥ | ៥.១៨ ប្រភេទផលិតផល WMC/RSMC | ប្រសិនបើ បាទ/ចាស សូមជ្រើសរើសប្រភេទផលិតផល៖ | ទិន្នន័យក្រឡាចត្រង្គ; គំនូសតាង; អត្ថបទ | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៦ | ៥.១៩ ការប្រើប្រាស់ទិន្នន័យក្រឡាចត្រង្គ | ប្រសិនបើអ្នកបានសម្គាល់ "ទិន្នន័យក្រឡាចត្រង្គ" នៅក្នុងសំណួរខាងលើ សូមជ្រើសរើសសកម្មភាពពាក់ព័ន្ធដែលអ្នកប្រើទិន្នន័យទាំងនេះសម្រាប់ | ដំណើរការលើ ក្រោយដំណើរការប្រតិបត្តិការម៉ូដែលតំបន់មានកំណត់ | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៧ | ការប្រើប្រាស់ការណែនាំ RSMCs | តើអ្នកប្រើផលិតផលណែនាំដែលផ្តល់ដោយ RSMCs ដែរឬទេ? (លុះ | បាទ/ចាស | | ទេ | ការវាយតម្លៃហើសរបស់ EW4All | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ត្រាតែពួកគេត្រូវបានគ្របដណ្តប់ដោយមួយ) | | | | | |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៨ | បុគ្គលិកត្រូវបានបណ្តុះបណ្តាលដើម្បីចូលប្រើ និងប្រើប្រាស់ផលិតផល WMCs/RCs និងការណែនាំសម្រាប់ការព្យាករអំពីគ្រោះថ្នាក់ | តើបុគ្គលិក NMHS ត្រូវបានបណ្តុះបណ្តាលដើម្បីចូលប្រើ និងប្រើប្រាស់ផលិតផល WMCs/RCs និងការណែនាំសម្រាប់ការព្យាករអំពីគ្រោះថ្នាក់ដែរឬទេ? | បាទ/ចាស | បើ បាទ/ចា, សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | បុគ្គលិកត្រូវបានបណ្តុះបណ្តាល ដើម្បីដំណើរការគំរូតំបន់មានកំណត់ (ARPEGE) ហើយក៏អាចចូលទៅកាន់ផលិតផលពី WMO RSMC, SWFP, TCP និង មជ្ឈមណ្ឌលអាកាសធាតុតូក្យូ |
| **ច. សមត្ថភាពក្នុងការព្យាករទូទៅ** | ច.០៩ | ចំនួនអ្នកព្យាករណ៍ដែលបានបណ្តុះបណ្តាលគ្រប់គ្រាន់ | តើមជ្ឈមណ្ឌលព្យាករណ៍របស់អ្នកមានចំនួនអ្នកព្យាករណ៍ដែលបានបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីផ្តល់សេវាព្រមានមុនឬទេ? | ទេ | | បាទ/ចាស | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០១ | 6.04 ការព្យាករ និងសេវាព្រមានផ្អែកលើផលប៉ះពាល់ដែលផលិត/ផ្តល់ដោយ NMS | តើ NMHS របស់អ្នកផលិត/ផ្តល់សេវាព្យាករណ៍ និងព្រមានដោយផ្អែកលើផលប៉ះពាល់ទេ? | ទេ | | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០២ | តើ NMHS ជាអ្នកផលិត/ផ្តល់សេវាព្យាករណ៍ និងព្រមានដល់ពេលទេ? | តើអ្នកព្យាករណ៍របស់អ្នកត្រូវបានបណ្តុះបណ្តាលលើគោលការណ៍ វិធីសាស្ត្រ និងការអនុវត្តរបស់ IBF ដែរឬទេ? | Few | | Yes | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០៣ | ការចូលប្រើព័ត៌មានស្តីពីផលប៉ះពាល់ | តើអ្នកមានសិទ្ធិទទួលបានព័ត៌មានស្តីពីផលប៉ះពាល់ (រាប់បញ្ចូលទាំងវិស័យនានា) និងការវិភាគក្រោយគ្រោះមហន្តរាយពីភាគីពាក់ព័ន្ធដើម្បីបញ្ចូលក្នុង IBF របស់អ្នកដែរឬទេ? | ទេ | សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០៤ | ម៉ូដែលផលប៉ះពាល់ជាក់លាក់នៃគ្រោះថ្នាក់ | តើអ្នកប្រើម៉ូដែលផលប៉ះពាល់គ្រោះថ្នាក់ជាក់លាក់ដែរឬទេ? | ទេ | | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០៥ | តើស្ថាប័នផ្សេងទៀតដែលទទួលខុសត្រូវចំពោះគំរូផលប៉ះពាល់ដែលឬទេ? | បើ ទេ តើទីភ្នាក់ងារ/ក្រសួងផ្សេងទៀតនៅក្នុងប្រទេសទទួលខុសត្រូវចំពោះការបង្កើតម៉ូដែលផលប៉ះពាល់ដែរឬទេ? (ដោយវិស័យគ្រោះថ្នាក់) | ទេ | | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០៦ | ៨.១៤ ព័ត៌មានអំពីគ្រោះថ្នាក់ ភាពប្រឈម និងភាពងាយរងគ្រោះ ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសជាធាតុចូលទៅក្នុងផែនការសង្គ្រោះបន្ទាន់ និងការបង្កើតសារប្រកាសអាសន្ន | តើ NMHS របស់អ្នកប្រើព័ត៌មានគ្រោះថ្នាក់ ភាពប្រឈម និងភាពងាយរងគ្រោះ ជាការបញ្ចូលទៅក្នុងការអភិវឌ្ឍផលិតផលប្រកាសអាសន្នដែរឬទេ? | ទេ | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF)** | ឆ.០៧ | ព័ត៌មានហានិភ័យដែលផ្តល់ដោយអាជ្ញាធរពាក់ព័ន្ធ | ប្រសិនបើ បាទ/ចាស តើព័ត៌មានបែបនេះត្រូវបានផ្តល់ដោយអាជ្ញាធរពាក់ព័ន្ធ (ឧ. ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយជាតិ) ក្នុងទម្រង់នៃផែនទីគ្រោះថ្នាក់/ហានិភ័យដែរឬទេ? | ទេ | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |
| **ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែក** | ឆ.០៨ | សារប្រកាសឱ្យដឹងមុនសម្រាប់គ្រោះថ្នាក់ជាអាទិភាពទាំងអស់ណែនាំអំពីសកម្មភាពដែលអាច | តើសារប្រកាសអាសន្នដែលផលិតដោយ NMHS របស់អ្នកផ្តល់ដំបូន្មានលើសកម្មភាពដែលអាច | បាទ/ចាស | បើ បាទ/ចាស, សូមបញ្ជាក់ | ទេ | ការវាយតម្លៃរហ័សរបស់ EW4All | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| លើផលប៉ះពាល់ជាក់ស្តែង (IBF) | | អនុវត្ត ដើម្បីកាត់បន្ថយហានិភ័យ | អនុវត្តបាន ដើម្បីកាត់បន្ថយហានិភ័យដែរឬទេ? | | | | | |
| ឆ. សមត្ថភាពអំពីការព្យាករ ដែលផ្អែកលើផលប៉ះពាល់ជាក់ស្តែង (IBF) | ឆ.0៩ | | តើ NMHS របស់អ្នកមានឧបករណ៍សូហ្វវែរ (software tools) គ្រប់គ្រាន់ ដើម្បីផលិតការព្យាករ និងការប្រកាសអាសន្នផ្អែកលើផលប៉ះពាល់ដែរឬទេ? | ទេ | បើ ទេ, សូមបញ្ជាក់ | ទេ | ការវាយតម្លៃហ័សរបស់ EW4All | ប្រព័ន្ធ IBF (ផ្នែករឹង និងទន់) ការវិភាគ ការសិក្សា និងការកសាងសមត្ថភាពគឺចាំបាច់ |
